# ច្រកកលានុវត្តភាពសម្រាប់អាងទន្លេមេគង្គ៖ អនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិគឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចសហប្រតិបត្តិការ

*ការវិភាគផ្លូវច្បាប់អំពីរបៀបដែលអនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិបំពេញបន្ថែមលើការអនុវត្តន៍កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥*



BRIDGE: ការបង្កើតកិច្ចពិភាក្សា និងគ្រប់គ្រងទន្លេ

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development and Cooperation SDC

BRIDGE

ការកំណត់នៃផ្នែកភូមិសាស្ត្រក្នុងសៀវភៅនេះ និងការបង្ហាញនៃឯកសារពុំមានបង្កប់នូវការបង្ហាញមតិយោបល់ណាមួយពីខាងអង្គការ IUCN (សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ និងធនធានធម្មជាតិ) ឬទីភ្នាក់ងារស៊ុីសដើម្បីការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងស្ថានភាពផ្លូវច្បាប់នៃប្រទេស ដែនដី ឬតំបន់ណាមួយ ឬអាជ្ញាធរនៃ តំបន់នោះ ឬពាក់ព័ន្ធនឹងការកំណត់នូវព្រំប្រទល់ ឬព្រំដែននៃតំបន់នោះឡើយ។
ទស្សនៈដែលបង្ហាញក្នុងការបោះពុម្ពផ្សាយនេះពុំឆ្លុះបញ្ចាំងពីទស្សនៈរបស់ទីភ្នាក់ងារស្វ៊ីសដើម្បីការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការឡើយ។
គម្រោង BRIDGE ត្រូវបានផ្តល់មូលនិធិដោយទីភ្នាក់ងារស្វ៊ីសដើម្បីការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ។

បោះពុម្ពផ្សាយដោយ៖
IUCN ការិយាល័យប្រចាំតំបន់អាស៊ី

រក្សាសិទ្ធិដោយ៖
©2016 សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ និងធនធានធម្មជាតិ

ការថតចម្លងឯកសារនេះសម្រាប់ ការអប់រំ ឬក្នុងគោលបំណងផ្សេងទៀតមិនមែនពាណិជ្ជកម្មផ្សេងទៀត គឺត្រូវបានអនុញ្ញាតដោយពុំត្រូវការការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីម្ចាស់រក្សាសិទ្ធិ ក្នុងករណីប្រភពត្រូវបានទទួលស្គាល់ពេញលេញ។ ការថតចម្លងឯកសារនេះក្នុងគោលបំណងលក់បន្ត ឬពាណិជ្ជកម្មផ្សេងទៀតត្រូវបានហាមឃាត់លើកលែងតែមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីម្ចាស់រក្សាសិទ្ធិឡើយ។

សេចក្តីស្រង់៖
Kinna, R. (២០១៦). ច្រកកលានុវត្តភាពសម្រាប់អាងទន្លេមេគង្គ៖ អនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិគឺជាមូលដ្ឋានគ្រឹះសម្រាប់កិច្ចសហប្រតិបត្តិការ (ការវិភាគផ្លូវច្បាប់អំពីរបៀបដែលអនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិអនុវត្តកិច្ចព្រមព្រៀងទន្លេមេគង្គ៖ IUCN. 27pp.

សេចក្តីពន្យល់នៅលើគ្របះ
ផែនទីទន្លេមេគង្គ. អាស៊ី IUCN  (2016).

ផលិតដោយ៖
ការិយាល័យតំបន់អាស៊ី IUCN

អាចរកបាននៅ៖
IUCN (សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ និងធនធានធម្មជាតិ)
ការិយាល័យប្រចាំតំបន់អាស៊ី
63 Sukhumvit Soi 39
ផ្លូវ Sukhumvit
Wattana បាងកក 10110
ប្រទេសថៃ
ទូរសព្ទ៖ +662 662 4029
http://www.iucn.org/about/union/secretariat/offices/asia/regional_activities/bridge_3s/

## ពាក្យបំព្រួញ

| | |
|---|---|
| ICJ | តុលាការយុត្តិធម៌អន្តរជាតិ |
| IWRM | ការគ្រប់គ្រងធនធានទឹករួមគ្នា |
| LMB | អាងទន្លេមេគង្គក្រោម |
| MA | កិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ |
| MRC | គណៈកម្មការទន្លេមេគង្គ |
| PNCPA | នីតិវិធីសម្រាប់ការជូនដំណឹង ពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង |
| UNWC | អនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិឆ្នាំ ១៩៩៧ |
| ILC | គណៈកម្មការច្បាប់អន្តរជាតិ |

## សន្ទានុក្រម

**អនុសញ្ញា៖** ការបង្កើតនូវកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរមួយដែលក្នុងនោះប្រទេសនានាដែលចូលរួមភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ខ្លួនឯងដើម្បីអនុវត្តក្នុងវិធីជាក់លាក់ណាមួយ ឬដើម្បីបង្កើតនូវទំនាក់ទំនងជាក់លាក់រវាងគ្នា។ ពាក្យនេះត្រូវបានប្រើប្រាស់ផ្លាស់ប្តូរគ្នាបានជាមួយនឹងពាក្យសន្ធិសញ្ញា។ សន្ធិសញ្ញាត្រូវបានគេស្គាល់តាមរយៈឈ្មោះផ្សេងៗគ្នាជាច្រើន ចាប់ពី កិច្ចព្រមព្រៀងអន្តរជាតិ ច្បាប់ និងធម្មសញ្ញាទូទៅ រហូតដល់ លក្ខន្តិកៈ ការប្រកាស និងអនុសញ្ញា។

**ច្បាប់អន្តរជាតិជាប្រពៃណី៖** បទប្បញ្ញត្តិកើតចេញពីទម្លាប់អនុវត្តទូទៅក្នុងចំណោមប្រទេសនានា អមជាមួយនូវជំនឿ ដែលថាទម្លាប់អនុវត្តនោះគឺភ្ជាប់កាតព្វកិច្ចច្បាប់ (សូមមើលការកំណត់កើតចេញពីទម្លាប់អនុវត្ត)។

**ការត្រួតពិនិត្យការបំពេញតួនាទី៖** ជំហាននានាដែលត្រូវអនុវត្តឱ្យបានសមស្រប (រួមបញ្ចូលទាំង ផ្នែកហិរញ្ញវត្ថុ ផ្លូវច្បាប់ បច្ចេកទេស និងរដ្ឋបាល) ដោយប្រទេសមួយដើម្បីទទួលបានការថែទាំប្រកបដោយស្តង់ដារស្របច្បាប់និងមានការទទួលស្គាល់ ដើម្បីជៀសវាងពីការបង្កព្យសនកម្មដល់ប្រទេសផ្សេងទៀត ។

**ការប្រើប្រាស់ស្មើភាព និងសមហេតុផល៖** ពាក្យស្មើភាព និងសមហេតុផលសំដៅជាទូទៅលើសិទ្ធិស្មើភាពក្នុងចំណោមប្រទេសនានាក្នុងការចែករំលែកផ្លូវទឹកអន្តរជាតិដើម្បីប្រើប្រាស់ទឹកសម្រាប់គោលបំណងជាអត្ថប្រយោជន៍ និងចីរភាពផ្ទាល់របស់ខ្លួន ពាក់ព័ន្ធនឹងប្រទេសផ្សេងទៀត។

**សុចរិត៖** កាប្រព្រឹត្តិទៅជាមួយនឹងបំណងស្មោះត្រង់ យុត្តិធម៌ និងទៀងត្រង់ ដោយពុំមានបំណងឆបោក។

**ការចូលជាធរមាន៖** សន្ធិសញ្ញាមួយក្លាយជា ឬចូលជាធរមាន នៅពេលដែលសន្ធិសញ្ញានោះភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះគូភាគីនៃសន្ធិសញ្ញា។ សន្ធិសញ្ញាមួយពុំចូលជាធរមានឡើយ នៅពេលដែលសន្ធិសញ្ញានោះត្រូវបានអនុម័ត (បើកចំហសម្រាប់ការចុះហត្ថលេខា)។ កាលបរិច្ឆេទនៃការចូលជាធរមានអាចជាកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងសន្ធិសញ្ញា ឬកាលបរិច្ឆេទនៅពេលដែលចំនួនជាក់លាក់មួយនៃសច្ចាប័ន ការឯកភាព ការទទួល ឬការចូលជាសមាជិកត្រូវបានដាក់នៅអ្នករក្សាទុក។

**យុត្តាធិការ៖** សិទ្ធិក្នុងច្បាប់អន្តរជាតិសម្រាប់ប្រទេសមួយក្នុងការអនុវត្តន៍សិទ្ធិអំណាចលើជាតិ មនុស្ស និងវត្ថុនៅក្នុងទឹកដីរបស់ខ្លួន។

**ការកំណត់កើតចេញពីទម្លាប់អនុវត្ត៖** ជំនឿទូទៅរបស់ប្រទេសមួយដែលបង្ហាញថា ទម្លាប់អនុវត្តរបស់ប្រទេសជាក់លាក់មួយគឺត្រូវបានភ្ជាប់កាតព្វកិច្ចច្បាប់។

**ការប្រើប្រាស់ប្រសើរបំផុត៖** ការប្រើប្រាស់អាចទៅរួចដែលល្អបំផុត ឬដែលចង់បានបំផុតក្រោមលក្ខខណ្ឌដាក់កំហិតជាក់លាក់ ឧបករណ៍ ការបំពេញតម្រូវការផលប្រយោជន៍នៃប្រទេសពីរ ឬច្រើន។

**ភាគី៖** ប្រទេស ឬអង្គភាពសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់មួយដែលបានយល់ព្រមភ្ជាប់កាតព្វកិច្ចដោយអនុសញ្ញានៅពេលចូលជាធរមាន។

**សច្ចាប័ន៖** តាមរយៈការចុះហត្ថលេខា ការបង្ហាញនៃការយល់ព្រមរបស់ប្រទេសមួយត្រូវបានភ្ជាប់កាតព្វកិច្ចដោយសន្ធិសញ្ញាមួយ។ ពាក្យសច្ចាប័នត្រូវបានប្រើប្រាស់ផ្លាស់ប្តូរគ្នាជាមួយពាក្យ "ចូលជាសមាជិក" "ការឯកភាព" និង "ការទទួល" ជាញឹកញាប់។

**ព្យសនកម្មធ្ងន់ធ្ងរ៖** អ្វីដែលលើសពីការប្រទះឃើញធម្មតា ប៉ុន្តែមិនឈានដល់កម្រិតធ្ងន់ធ្ងរ ឬខ្លាំងក្លា។ ព្យសនកម្មដែលសំខាន់ គឺត្រូវបង្កផលប៉ះពាល់ពិតចំពោះមនុស្ស ឧស្សាហកម្ម ទ្រព្យសម្បត្តិ បរិស្ថាន ឬកសិកម្ម។

**ការប្រើប្រាស់ប្រកបដោយចីរភាព៖** មានធាតុសំខាន់ៗពីរក្នុងបរិបទនៃធនធានធម្មជាតិគឺ៖ ការប្រើប្រាស់ប្រកបដោយវិចារណញ្ញាណ និងការការពារនៃប្រព័ន្ធអេកូឡូស៊ី។ ក្នុងបរិបទនៃធនធានដែលអាចធ្វើថ្មីបាន វាមានន័យថាការពារភាពអាចផ្តល់អត្ថប្រយោជន៍រយៈពេលវែងនៃធនធានសម្រាប់ជំនាន់នេះ និងធនធានសម្រាប់អ្នកជំនាន់ក្រោយ។

## មាតិកា


បុព្វកថា......6

**ខ្លឹមសារសង្ខេបប្រតិបត្តិ......7**

1 ប្រវត្តិ......8

1.1 UNWC៖ ប្រវត្តិ និងទិដ្ឋភាពទូទៅ......8

1.1.1 ការវិវត្តន៍......9

1.1.2 ទិដ្ឋភាពទូទៅ......9

1.1.3 គោលការណ៍......9

1.1.4 នីតិវិធី......9

1.1.5 ការអនុម័ត និងការចូលជាធរមាន......9

1.2 កិច្ចព្រមព្រៀងទន្លេមេគង្គ៖ ប្រវត្តិ និងទិដ្ឋភាពទូទៅ......10

1.2.1 ការវិវត្តន៍......10

1.2.2 ទិដ្ឋភាពទូទៅ......10

1.2.3 គោលការណ៍......10

1.2.4 នីតិវិធី......10

1.2.5 ការអនុម័ត និងការចូលជាធរមាន......11

1.3 គណៈកម្មការទន្លេមេគង្គ (MRC)......12

1.3.1 ទិដ្ឋភាពទូទៅ......12

1.3.2 រចនាសម្ព័ន្ធ និងអាណត្តិ......12

1.3.3 មុខងារ......11

1.3.4 សភាព......12

2 UNWC និងកិច្ចព្រមព្រៀងទន្លេមេគង្គ៖ ការវិភាគផ្លូវច្បាប់ប្រៀបធៀប......13

2.1 វិសាលភាព និងនិយមន័យ......14

2.2 គោលការណ៍ជាក់លាក់៖ ការអភិវឌ្ឍប្រកបដោយចីរភាព......14

2.3 គោលការណ៍ជាក់លាក់៖ ការប្រើប្រាស់ស្មើភាព និងសមហេតុផល......15

2.4 គោលការណ៍ជាក់លាក់៖ កាតព្វកិច្ចមិនបង្កព្យសនកម្មធ្ងន់ធ្ងរ (និងភារកិច្ចពាក់ព័ន្ធក្នុងការការពារប្រព័ន្ធអេកូឡូស៊ី)......16

2.5 កាតព្វកិច្ចខាងនីតិវិធី៖ គោលការណ៍នៃកិច្ចសហប្រតិបត្តិការ និងការផ្លាស់ប្តូរព័ត៌មាន......17

2.6 កាតព្វកិច្ចខាងនីតិវិធី៖ គោលការណ៍នៃការជូនដំណឹងជាមុន ការប្រឹក្សាយោបល់ និងការចរចា (លើវិធានការដែលបានគ្រោងទុក)......18

2.7 កាតព្វកិច្ចខាងនីតិវិធី៖ នីតិវិធីនៃការដោះស្រាយវិវាទ......20

3 អភិបាលកិច្ចគាំទ្ររបស់ UNWC ក្នុងទន្លេមេគង្គ និងតំបន់ខាងក្រៅ......21

3.1 គំលាតក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គ និង MRC......21

3.2 UNWC នឹង*ពង្រឹង* មិនមែនជំនួសកិច្ចព្រមព្រៀងទន្លេមេគង្គឡើយ......22

3.3 UNWC នឹង*សម្រប* កិច្ចព្រមព្រៀងទន្លេមេគង្គជាមួយនឹងច្បាប់ប្រពៃណី......22

3.4 UNWC នឹង*ពង្រឹង* មិនមែនបន្សោយអាណត្តិ MRC ដើម្បីធ្វើអភិបាលកម្មឡើយ......22

3.5 UNWC នឹង*ពង្រឹង* មិនមែនបន្សោយកិច្ចសហប្រតិបត្តិនៅក្នុង និងតាមរយៈ MRC ឡើយ......23

4 សេចក្តីសន្និដ្ឋាន និងអនុសាសន៍......23

4.1 អនុសាសន៍ចម្បង......24

ឯកសារយោង......25

## បុព្វកថា

គម្រោង BRIDGE (ការបង្កើតកិច្ចសន្ទនា និងអភិបាលកិច្ចទន្លេ) ត្រូវបានជួយសម្រួលដោយអង្គការ IUCN (សហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ) និងត្រូវបានគាំទ្រដោយកម្មវិធីកិច្ចការទូតទឹកនៃទីភ្នាក់ងារដើម្បីការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ (SDC) របស់ប្រទេសស្វីស។ គម្រោងនេះមានគោលដៅកសាងសមត្ថភាពអភិបាលកិច្ចទឹកតាមរយៈការសិក្សា ការបង្ហាញ ភាពជាអ្នកដឹកនាំ និងការស្របមតិគ្នានូវចំណុចក្តៅក្នុងតំបន់អាងទន្លេឆ្លងដែន។ នេះគឺជាគម្រោងពហុតំបន់មួយដែលត្រូវបានអនុវត្តក្នុងតំបន់អាងជាច្រើននាអាមេរិកខាងត្បូង និង Meso អាហ្វ្រិក និងអាស៊ី។

នៅអាស៊ី គម្រោង BRIDGE បានដំណើរការក្នុងតំបន់ទន្លេមេគង្គតាំងពីឆ្នាំ ២០១១ ហើយត្រូវបានផ្តល់ឱ្យនូវឱកាសសម្រាប់កិច្ចពិភាក្សា និងការបណ្តុះបណ្តាលស្តីពីកិច្ចការទូតទឹកសម្រាប់ភាគីចូលរួមចម្បងៗ ក៏ដូចជាបានសម្រួលនូវការចែករំលែកព័ត៌មានស្តីពីការគ្រប់គ្រងធនធានទឹករួមគ្នា (IWRM) និងបានបង្កើតទិន្នន័យ រួមទាំងការសិក្សាដើម្បីគាំទ្រដល់ការពិភាក្សាបច្ចេកទេសទូទាំងអាង។

BRIDGE បង្កើតនូវកម្លាំងជំរុញផ្នែកនយោបាលក្នុងការគាំទ្ររដ្ឋាភិបាលជាតិឱ្យទទួលស្គាល់ និងប្តេជ្ញាអនុវត្តតាមគោលការណ៍ច្បាប់ដែលផ្តល់ដោយអនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិឆ្នាំ ១៩៩៧ និងអនុសញ្ញាសហប្រជាជាតិទឹកនៃ UNECE ឆ្នាំ ១៩៩២។

ជាផ្នែកមួយនៃការខិតខំប្រឹងប្រែងនេះ BRIDGE ផ្តល់សិក្ខាសាលាបណ្តុះបណ្តាលលើប្រធានបទមួយចំនួនពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការទឹកឆ្លងដែនរួមបញ្ចូលទាំងច្បាប់ទឹកអន្តរជាតិ បើនិយាយជាទូទៅ និង UNWC បើនិយាយជាក់លាក់។ គោលបំណងនៃការបណ្តុះបណ្តាលទាំងនេះ គឺដើម្បីផ្តល់ឱ្យមន្ត្រី និងតំណាងទីភ្នាក់ងារចម្បងដែលពាក់ព័ន្ធនឹងសង្គមស៊ីវិល និងវិស័យឯកជនមានការយល់ដឹងកាន់តែប្រសើរអំពីច្បាប់ទឹកអន្តរជាតិ និងបទប្បញ្ញត្តិចម្បងៗ បទបញ្ញាដែលជាក់លាក់ និងខាងនីតិវិធី ព្រមទាំងទស្សនៈវិស័យរបស់ស្ថាប័ននៃ UNWC។

ឯកសារដែលផ្អែកលើការវិភាគផ្លូវច្បាប់ដោយ Rémy Kinna មកពី TWL Global Consulting នេះគឺជាផ្នែកមួយនៃកញ្ចប់បណ្តុះបណ្តាលដែលគាំទ្រដល់ការបណ្តុះបណ្តាលនៃ BRIDGE ស្តីពីកិច្ចការទូតទឹក។ ឯកសារនេះត្រូវបានផលិតឡើងតាមការស្នើសុំរបស់អ្នកឯកទេស និងដៃគូរបស់ BRIDGE ក្នុងតំបន់អាងទន្លេមេគង្គក្រោម ហើយនឹងត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលបណ្តុះបណ្តាលរបស់ BRIDGE។ ឯកសារនេះក៏នឹងត្រូវបានផ្សព្វផ្សាយឱ្យទូលំទូលាយក្នុងបណ្តាលប្រទេសនៃអាងទន្លេមេគង្គក្រោមផងដែរ។

BRIDGE ប្រមើលថា ឯកសារនេះនឹងពង្រឹងបន្ថែមនូវគោលការណ៍នៃ UNWC និងភាពស្របគ្នាជាមួយនឹងកិច្ចព្រមព្រៀងមេគង្គ ហើយនឹងចូលរួមចំណែកក្នុងកិច្ចពិភាក្សាប្រចាំតំបន់ស្តីពីកិច្ចសហប្រតិបត្តិការទឹកឆ្លងដែន។

## ខ្លឹមសារសង្ខេបប្រតិបត្តិ

អនុសញ្ញាសហប្រជាជាតិស្តីពីផ្លូវទឹកអន្តរជាតិ (UNWC) បានចូលជាធរមានក្នុងខែសីហា ឆ្នាំ២០១៤ នៅពេលប្រទេសវៀតណាមបានក្លាយទៅជាប្រទេសទី ៣៥ ដែលផ្តល់សច្ចាប័នចំពោះ UNWC។ នេះគឺជាព្រឹត្តិការណ៍សំខាន់មួយសម្រាប់ការគ្រប់គ្រងជាសកលនូវទឹកឆ្លងដែន និងជាឱកាសសំខាន់មួយសម្រាប់បណ្តាប្រទេស និងតំបន់នានា ដែលពុំទាន់មានក្របខណ្ឌគ្រប់គ្រងកិច្ចសហប្រតិបត្តិការលើការចែករំលែកទឹក។

ការតាក់តែងច្បាប់អន្តរជាតិជាប្រពៃណី UNWCត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៧ ដោយផ្តល់នូវភាពច្បាស់លាស់ពាក់ព័ន្ធនឹងការអនុវត្តន៍នៃច្បាប់ទឹកអន្តរជាតិ។ ដោយត្រូវបានកំណត់ជាអនុសញ្ញាក្របខណ្ឌសកល គោលបំណងស្នូលនៃអនុសញ្ញានេះគឺដើម្បីផ្តល់នូវក្របខណ្ឌច្បាប់ដែលអាចបត់បែនបាន អាចបង្កើតសន្ធិសញ្ញាអាងទន្លេ និង/ឬផ្លូវទឹកកាន់តែជាក់លាក់ ដើម្បីផ្តល់នូវយន្តការគ្រប់គ្រងកាន់តែលម្អិតតាមរយៈបទប្បញ្ញត្តិជាក់លាក់លើបរិបទ និងក្របខណ្ឌគោលនយោបាយដែលពុំភ្ជាប់កាតព្វកិច្ច ពាក់ព័ន្ធនានា។

ក្នុងតំបន់ទន្លេមេគង្គ សន្ធិសញ្ញាជាក់លាក់លើអាងទន្លេគឺ កិច្ចព្រមព្រៀងមេគង្គ។ ដោយបានចូលជាធរមានក្នុងឆ្នាំ ១៩៩៥ កិច្ចព្រមព្រៀងមេគង្គត្រូវបានអនុម័តដោយប្រទេសនៃអាងទន្លេមេគង្គក្រោម (LMB) រួមមាន ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម ព្រមទាំងអមជាមួយនឹងការបង្កើតស្ថាប័នអាងអន្តររដ្ឋាភិបាល ហៅថា គណៈកម្មការទន្លេមេគង្គ (MRC)។ សន្ធិសញ្ញានេះដើមដំបូងត្រូវបានបង្កើតឡើងជា "ក្របខណ្ឌស្ថាប័នវឌ្ឍនភាពទៅមុខបំផុតសម្រាប់ការគ្រប់គ្រងផ្លូវទឹកអន្តរជាតិ"[1] នាពេលនោះ ហើយអមជាមួយ MRC ត្រូវបាន "កោតសរសើរជាគំរូសម្រាប់ពិភពលោក"[1]។ ប៉ុន្តែ ២០ ឆ្នាំក្រោយ សមត្ថភាពនៃកិច្ចព្រមព្រៀងមេគង្គ និង MRC ក្នុងការគ្រប់គ្រងផ្លូវទឹកឆ្លងដែនប្រកបដោយប្រសិទ្ធភាពនៅក្នុងតំបន់ជួបប្រទះនឹងបញ្ហា ជាពិសេស ទាក់ទងនឹងវិវាទដែលពាក់ព័ន្ធនឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃទំនប់វារីអគ្គិសនីតាមដងទន្លេ និងបណ្តាដៃទន្លេ។

ការចូលជាធរមាននៃ UNWC បង្ហាញនូវឱកាសមួយក្នុងការស្វែងរកដំណោះស្រាយរួមដើម្បីពង្រឹងការគ្រប់គ្រងទឹកឆ្លងដែនទាំងក្នុងតំបន់អាងទន្លេមេគង្គ និងជាសកល។ គ្រប់ប្រទេសក្នុងតំបន់អាងបានភ្ជាប់កាតព្វកិច្ចដោយគោលការណ៍នៃច្បាប់ប្រពៃណីអន្តរជាតិដែលត្រូវបានតាក់តែងឡើងក្រោម UNWC។ ជាលទ្ធផល ប្រទេសនានាដែលឱ្យសច្ចានុមតិ និងអនុវត្ត UNWC នឹងពុំមានឃើញអ្វីផ្លាស់ប្តូរក្នុងកាតព្វកិច្ចជាមូលដ្ឋានរបស់គេឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសទាំងនោះនឹងទទួលបានផលប្រយោជន៍ពីក្របខណ្ឌអាចពង្រឹងបានដែលពុំទាន់មាននៅក្នុងកិច្ចព្រមព្រៀងមេគង្គ។ វានឹងផ្តល់នូវភាពស៊ីសង្វាក់គ្នាក្នុងតំបន់អាងទាំងមូលក្នុងការគ្រប់គ្រង និងនិយ័តកម្មប្រកបដោយប្រសិទ្ធភាពនៃការអនុវត្តន៍របស់ប្រទេសនៅតាមដងទន្លេ។ វានឹងទ្រទ្រង់ដល់ប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោមផងដែរ ពីព្រោះប្រទេសទាំងនេះស្វែងរកកិច្ចពិភាក្សាកាន់តែមានតុល្យភាពជាមួយនឹងប្រទេសនានានៅខ្សែទឹកខាងលើដែលនៅពុំទាន់ជាផ្នែកនៃកិច្ចព្រមព្រៀងមេគង្គ និង MRC នៅឡើយ។

លិខិតនេះផ្តល់នូវការវិភាគប្រៀបធៀបមួយនៃគោលការណ៍ និងកាតព្វកិច្ចច្បាស់លាស់ និងខាងនីតិវិធីចម្បងនានាដែលបានផ្តល់ឱ្យក្នុងសន្ធិសញ្ញាទាំងពីរ។

លទ្ធផលគឺជាការស្វែងរកនូវភាពស្របគ្នាផ្នែកច្បាប់ទូទៅទាំងមូលរវាង UNWC និងកិច្ចព្រមព្រៀងមេគង្គ។ លើសពីនេះទៅទៀត នៅពេលមានគំលាត និងភាពមិនស៊ីសង្វាក់គ្នារវាងលិខិតុបករណ៍ទាំងនេះ UNWC នឹងដោះស្រាយវា។ ជាពិសេស នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNCPA) នៃកិច្ចព្រមព្រៀងមេគង្គ ដែលមានសារៈសំខាន់បំផុតសម្រាប់ការដោះស្រាយវិវាទ គឺជាផ្នែកខាងក្រៅនៃកិច្ចព្រមព្រៀង ហើយជាលទ្ធផល គឺពុំភ្ជាប់កាតព្វកិច្ចឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ គំលាតក្នុងការពង្រឹងនេះត្រូវបានដោះស្រាយតាមរយៈបទប្បញ្ញត្តិច្បាប់ច្បាស់លាស់នៃ UNWC។

លទ្ធផលនៃការវិភាគបង្ហាញយ៉ាងច្បាស់នូវអត្ថប្រយោជន៍នៃការឱ្យសច្ចានុមតិលើ UNWC ដោយប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោម និងសមាជិកនៃ MRC។ វាផ្តល់អនុសាសន៍បន្ថែមទៀតថា UNWC នឹងពង្រឹងបន្ថែម ជាជាងជំនួសឱ្យកិច្ចព្រមព្រៀងមេគង្គ និង MRC ព្រមទាំងពង្រឹងនូវឥទ្ធិពលស្តង់ដារកាន់តែទូលំទូលាយរបស់ខ្លួនទៅជាលិខិតុបករណ៍សំខាន់បំផុតសម្រាប់ការគ្រប់គ្រងជាសកលនូវផ្លូវទឹកឆ្លងដែន។

---

[1] Ibid., p. 803

# 1 ប្រវត្តិ

*អនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់ប្រើប្រាស់ផ្លូវទឹកអន្តរជាតិដែលពុំមានការស្វែងមើលទិសដៅ* (UNWC) គឺជាប្រភពចម្បងនៃច្បាប់អន្តរជាតិនៅកម្រិតសកលសម្រាប់ការគ្រប់គ្រងនូវការប្រើប្រាស់ទន្លេទឹកសាបឆ្លងដែន។ សន្ធិសញ្ញានានាដែលមានស្រាប់ (ប្រចាំតំបន់ តំបន់អាង ទ្វេភាគី) និងច្បាប់អន្តរជាតិត្រួតពីលើ UNWC ដើម្បីបង្កើតនូវរបបច្បាប់ពេញលេញសម្រាប់ច្បាប់ផ្លូវទឹកអន្តរជាតិ។

ទំនាក់ទំនងជាសកលនៃច្បាប់ទឹកអន្តរជាតិបានកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីពាក់កណ្តាលសតវត្សទី ២០ ហើយជាចុងបញ្ចប់ UNWC បានចូលជាធរមានក្នុងឆ្នាំ ២០១៤។ ការចូលជាធរមាននេះតំណាងឱ្យព្រឹត្តិការណ៍យ៉ាងសំខាន់ក្នុងការអភិវឌ្ឍក្របខណ្ឌច្បាប់ និងការគ្រប់គ្រងជាសកលនូវទឹកឆ្លងដែន។ ការចូលជាធរមាននៃ UNWC បានបន្ថែមសារៈសំខាន់សម្រាប់តំបន់ទន្លេមេគង្គ ប្រសិនបើប្រទេសវៀតណាម ដែលជាប្រទេសតាមដងទន្លេមេគង្គ និងជាប្រទេសសមាជិកនៃកិច្ចព្រមព្រៀងមេគង្គ បានក្លាយទៅជាប្រទេសទី ៣៥ ដែលឱ្យសច្ចានុមតិលើ UNWC ដែលធ្វើឱ្យវាចូលជាធរមាន។

ទន្លេមេគង្គ និងដៃទន្លេមួយចំនួនដែលមានលក្ខណៈឆ្លងដែនពីធម្មជាតិ ហូរកាត់ប្រទេសចំនួនប្រាំមួយ (ប្រទេសចិន មីយ៉ាន់ម៉ា កម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ថៃ និងវៀតណាម) ហើយធនធានរបស់វាមានឥទ្ធិពលទៅលើការរស់នៅរបស់ប្រជាជនជាង ៧០លាននាក់។ កិច្ចព្រមព្រៀងមេគង្គ ជាសិន្ធិសញ្ញាថ្នាក់តំបន់ស្តីពីទឹកដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៥ ដើម្បីគ្រប់គ្រងការអភិវឌ្ឍទន្លេប្រកបដោយចីរភាពរវាងប្រទេសនៅតាមដងទន្លេ ដែលបច្ចុប្បន្នរួមបញ្ចូលនូវប្រទេសនៃអាងទន្លេមេគង្គក្រោមដូចជា កម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ថៃ និងវៀតណាម។ ប្រទេសនៅតាមដងទន្លេខ្សែទឹកខាងលើដូចជាចិន និងភូមា ត្រូវបានអញ្ជើញចូលរួម ប៉ុន្តែពុំទាន់ជាសមាជិកទេ។ គណៈកម្មការទន្លេមេគង្គ (MRC) ក៏ត្រូវបានបង្កើតឡើងផងដែរដោយកិច្ចព្រមព្រៀងមេគង្គឱ្យទៅជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសនៃអាងទន្លេដើម្បីគ្រប់គ្រងលើការប្រើប្រាស់ទន្លេដោយប្រសិទ្ធភាពតាមរយៈ UNWC ដែលមានអានុភាពអនុវត្តនាពេលបច្ចុប្បន្ន ដែលត្រូវបាន" ប្រមើលឃើញយ៉ាងច្បាស់ថានឹងមានផលប៉ះពាល់គួរឱ្យកត់សម្គាល់ទៅលើការគ្រប់គ្រងទឹកនៅអាងទឹកឆ្លងដែនជុំវិញពិភពលោកតាមរយៈការពង្រីកវិសាលភាពនៃសន្ធិសញ្ញាថ្នាក់តំបន់ដែលចូលជាធរមានរួចហើយតាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងជម្រុញប្រទេសថ្មីឱ្យចូលក្នុងអនុសញ្ញា"[2]។ **តួនាទីរបស់ UNWCក្នុងការគាំទ្រសន្ធិសញ្ញាដែលមានស្រាប់ មានសារៈសំខាន់ជាពិសេសពីព្រោះ បើទោះបីជាកិច្ចព្រមព្រៀងស្តីពីអាងទន្លេមាននៅទីណាក៏ដោយ កិច្ចព្រមព្រៀងទាំងនោះ តែងតែនៅខ្វះនូវគោលការណ៍ ឬនីតិវិធីនៃច្បាប់ទឹកអន្តរជាតិដែលអាចទទួលយកបានមួយចំនួន ឬមិនមានប្រទេសអាងទន្លេទាំងអស់ជាភាគី។ នេះគឺជាករណីនៅក្នុងទន្លេមេគង្គ ដែលចិន និងភូមាមិនមែនជាភាគីនៃកិច្ចព្រមព្រៀងមេគង្គ។**

## 1.1 UNWC៖ *សវតា* និងសេចក្តីសង្ខេប

UNWC ជាឯកសារស្នូលសម្រាប់មូលហេតុមួយចំនួន៖ វាបង្កើតក្របខណ្ឌរឹងមាំសម្រាប់ការរៀបចំការគ្រប់គ្រងទឹក និងមូលហេតុគោលរួមដែលពង្រឹងភាពប្រមាណទុកបាន និងជម្រុញបដិការដែលវាចងជាក្រម និងស្រាយបំភ្លឺនិយាមដែលមានស្រាប់ និងអភិវឌ្ឍគោលការណ៍លេចធ្លោនៃច្បាប់ទឹកអន្តរជាតិតាមប្រពៃណី។ វាគឺជាម៉ូដែលមួយដែលអាចជាមគ្គុទ្ទេសក៏សម្រាប់ការបកស្រាយសន្ធិសញ្ញា និងការចចារនិងសេចក្តីព្រៀងសន្ធិសញ្ញានាពេលអនាគតដទៃទៀតហើយវាបានតម្រែតម្រង់សេចក្តីវិនិច្ឆ័យរបស់តុលាការអន្តរជាតិ និងថ្នាក់តំបន់។

ប្រមាណ៩០% នៃផ្លូវទឹកអន្តរជាតិទាំង ២៦៥ នៅលើពិភពលោកបច្ចុប្បន្នគឺជាប្រភពនៃសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងអន្តរជាតិ។ កិច្ចព្រមព្រៀងស្តីពីទឹកឆ្លងព្រំដែន ជាទូទៅមានលក្ខណៈតំបន់ និងទ្វេភាគី និងត្រូវបានអភិវឌ្ឍចុះហត្ថលេខា និងផ្តល់សច្ចាប័នយ៉ាងទូលំទូលាយដោយប្រទេសដែលមានព្រំដែនជាប់គ្នា ឬបញ្ចូលគ្នាទាំងនោះដែលជាផ្លូវទឹកអន្តរជាតិកំពុងចោទជាបញ្ហា។ កិច្ចព្រមព្រៀងថ្មីៗមួយចំនួនត្រូវបានផ្អែកយ៉ាងទូលំទូលាយទៅលើបទប្បញ្ញត្តិរបស់ UNWC។

កិច្ចព្រមព្រៀងទាំងនេះ គឺជាផ្នែកទាំងមូលនៃស្ថាបត្យកម្មច្បាប់ដ៏ធំ ដែលតាមរយៈនេះផ្លូវទឹកអន្តរជាតិត្រូវបានគ្រប់គ្រងទាំងស្រុងដោយប្រទេស (ជាភាគីនៃលិខិតូបករណ៍ច្បាប់ និងភាគីដែលអនុវត្តលិខិតូបករណ៍ទាំងនោះមុនគេ)។ ស្ថាប័នអាងទន្លេ (ជាស្ថាប័នដែលតាមដាន

[2] Litke&Rieu-Clarke, 4 Feb 2015

ការលើកកម្ពស់សន្និសញ្ញា និងការគ្រប់គ្រងអាងទន្លេ) និងអង្គភាពដោះស្រាយជម្លោះ ដូចជាតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ជាផ្លូវតុលាការដំបូងគេសម្រាប់ការដោះស្រាយជម្លោះផ្លូវទឹកអន្តរជាតិ។ តួនាទី និងភារកិច្ចរៀងៗខ្លួនរបស់ស្ថាប័នទាំងនេះក្នុងការបង្កើតអង្គស្ថាបត្យកម្មច្បាប់សម្រាប់គ្រប់គ្រងផ្លូវទឹកអន្តរជាតិ ត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកគន្លឹះជាក្របខណ្ឌទូទៅនៃ UNWC ដើម្បីអនុញ្ញាតឱ្យពួកគេអាចប្រគល់នូវការគ្រប់គ្រងអាងទន្លេតាមបរិបទ។

### 1.1.1 វិវត្តន៍

អង្គការសហប្រជាជាតិបានចាប់ផ្តើមនិយាយអំពីសារៈសំខាន់នៃទន្លេឆ្លងដែននៅក្នុងច្បាប់អន្តរជាតិក្នុងឆ្នាំ១៩៥៩ នៅពេលដែលមហាសន្និបាតនៃអង្គការសហប្រជាជាតិ (UNGA) បានអនុម័តយល់ព្រមលើដំណោះស្រាយដែលអំពាវនាវឱ្យមានការសិក្សាបឋមស្តីពីបញ្ហាផ្លូវច្បាប់ទាក់ទងនឹងការប្រើប្រាស់ទន្លេអន្តរជាតិ។ ការសិក្សា ការចចារ ការព្រាងសេចក្តីធានាអះអាង និងដំណោះស្រាយបន្តបន្ទាប់ឡើងរហូតដល់សមាគមច្បាប់អន្តរជាតិ (ILA) ដែលបង្កើតវិធាន Helsinki ដំបូងគេនៅឆ្នាំ ១៩៦៦។ បើទោះបីជាមានការបោះជំហានទៅមុខសម្រេចបានដោយ ILA នៅក្នុងការចចារ និងព្រាងវិធាន Helsinki ក៏ដោយ វាបានអូសបន្លាយរហូតដល់ឆ្នាំ១៩៧០ ពោលគឺ ១១ ឆ្នាំបន្ទាប់ពីបញ្ជូនរឿងទៅធ្វើការសិក្សាបន្ថែមផ្នែកច្បាប់សម្រាប់ UNGA ដើម្បីតែងតាំងគណៈកម្មការច្បាប់អន្តរជាតិ (ILC) ឱ្យកាន់ភារកិច្ចបន្តបន្ទាប់លើការរៀបចំអនុសញ្ញាស្តីពីផ្លូវទឹកសម្រាប់អនុម័ត។ ដំណើរការដ៏ស្មុគស្មាញ និងផ្ទិតផ្ទង់នៃការចចារ និងការព្រមព្រៀងលើគោលការណ៍ និងបទប្បញ្ញត្តិគន្លឹះនៃឯកសារព្រាងដែលបានតាមដានមិនភាពមិនពេញលេញរហូតដល់ឆ្នាំ**១៩៩៤។ ត្រូវបានបន្ថែមរយៈពេលបីឆ្នាំដល់ការពិភាក្សាទៅលើប្រការព្រាង មុននឹង** UNGA **បានចុះលើដីកាដំណោះស្រាយលេខ** ៥១/២២៩ ដែលអនុម័តលើ UNWC នាថ្ងៃទី ២១ ខែឧសភាឆ្នាំ១៩៩៧។

### 1.1.2 សេចក្តីសង្ខេប

គោលដៅចម្បងរបស់ UNWC គឺចងក្រងនិយាមអន្តរជាតិទាក់ទងនឹងការប្រើប្រាស់មិនមែននាវាចរណ៍នៃផ្លូវទឹកអន្តរជាតិ។ ចំណុចនេះត្រូវបានសង្ខេបនៅក្នុងបុព្វកថាជាមួយនឹងគោលដៅដូចដែលបានចែងដើម្បី "ធានាការប្រើប្រាស់ ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រង និងការការពារផ្លូវទឹកអន្តរជាតិ និងលើកកម្ពស់ការប្រើប្រាស់តាមលទ្ធភាព និងប្រកបដោយចីរភាពនៃផ្លូវទឹកទាំងនោះសម្រាប់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត" និងគិតគូរអំពី "ស្ថានភាព និងតម្រូវការពិសេសរបស់ប្រទេសអភិវឌ្ឍ"។ ផ្លូវទឹកអន្តរជាតិត្រូវបានកំណត់នៅក្នុងមាត្រា ២ នៃ UNWC រាប់បញ្ចូលទាំងទឹកនៅលើផ្ទៃដី និងក្រោមដី ដែលមានផ្លូវទឹកក្រោមដីជាផ្នែកសំខាន់នៃផ្លូវទឹកលើដីនៅក្នុងប្រព័ន្ធអេកូឡូស៊ីតាមច្រាំងដងទន្លេ។

### 1.1.3 គោលការណ៍

ខ្លឹមសារសំខាន់នៃ UNWC ផ្នែកទី II បង្កើតគោលការណ៍ទូទៅ និងផ្តើមដោយអ្វីដែលមើលឃើញថាជាបទប្បញ្ញត្តិមានសារៈសំខាន់បំផុតនៅក្នុងអត្ថបទទាំងមូលៈ ការប្រើប្រាស់ស្មើភាព និងសមហេតុផល និងការចូលរួម (មាត្រា ៥-៦)។ គោលការណ៍ដែលមានជម្លោះច្រើនបំផុតនៅក្នុង UNWC គឺកាតព្វកិច្ចរបស់ប្រទេសក្នុងការ "ចាត់វិធានការសមស្របទាំងអស់" (មាត្រា ៧) ក្នុងការប្រើប្រាស់ផ្លូវទឹកអន្តរជាតិដោយមិនបង្កការប៉ះពាល់គួរឱ្យកត់សម្គាល់ដល់ប្រទេសនៅតាមដងទន្លេ។ ទំនាក់ទំនងរវាងគោលការណ៍មិនប៉ះពាល់គួរឱ្យកត់សម្គាល់ និងការប្រើប្រាស់ស្មើភាព និងសមហេតុផលនេះ កម្រត្រូវបានលើកឡើងជាស្នូលនៃកិច្ចពិភាក្សារវាងប្រទេសនៅតាមដងទន្លេខាងលើ និងក្រោមណាស់ មិនមែនត្រឹមតែក្នុងអត្ថបទ UNWC ប៉ុណ្ណោះទេ តែថែមទាំងទាក់ទងនឹងសន្និសញ្ញាស្តីពីអាងទន្លេទៀតផង ដូចជាកិច្ចព្រមព្រៀងមេគង្គ។

### 1.1.4 នីតិវិធី

ផ្នែក III នៃ UNWC ចែងអំពីគោលការណ៍ណែនាំនៃនីតិវិធី ដូចជាកាតព្វកិច្ចជូនដំណឹងជាមុនត្រូវបានតាមដាននៅពេលចាប់ផ្តើមវិធានការថ្មីដែលបានគ្រោងណាមួយនៅក្នុងប្រទេសមួយ ដែលអាចមានផលប៉ះពាល់អាក្រក់គួរកត់សម្គាល់ទៅលើប្រទេសនៅតាមដងទន្លេដែលមានផ្លូវទឹករួមគ្នា។ ដូច្នេះវាគួសបញ្ជាក់នូវបទប្បញ្ញត្តិសំខាន់ៗស្តីពីបរិស្ថាន ដោយទាត់ចោលនូវកាតព្វកិច្ចដែលមានគុណវឌ្ឍត្រឹមត្រូវសម្រាប់ប្រទេសដើម្បី "ការពារ និងអភិរក្សប្រព័ន្ធអេកូឡូស៊ីនៃផ្លូវទឹកអន្តរជាតិ" (ប្រការ ២០)។ UNWC ក៏គូសបញ្ជាក់ផងដែរនូវកាតព្វកិច្ចដែលប្រទេសត្រូវជូនដំណឹងភ្លាមដល់ប្រទេសដទៃអំពីលក្ខខណ្ឌប៉ះពាល់ និងស្ថានការណ៍បន្ទាន់ ដែលអាចប៉ះពាល់ដល់ប្រទេសទាំងនោះ (ប្រការ ២៧ និង ២៨)។ ចុងបញ្ចប់ វាប្រព្រឹត្តិទៅជាមួយការសម្រួលជាលក្ខខណ្ឌឯកជន និងនីតិវិធីដោះស្រាយជម្លោះ ដោយអនុញ្ញាតឱ្យប្រទេសទាំងនោះដេញដោលនីតិវិធីតុលាការ និង/ឬរដ្ឋបាលប្រឆាំងនឹងប្រទេសមួយផ្សេងទៀត និងចាត់នីតិវិធីដោះស្រាយ

ជម្លោះស្វ័យប្រវត្តិ ដោយខានមិនបាន ប្រសិនបើការចចារមិនត្រូវបានដោះស្រាយក្នុងរយៈពេលប្រាំមួយខែ (ប្រការ ៣២ និង ៣៣)។ ឧបសម្ព័ន្ធនៃ UNWC គូសបញ្ជាក់អំពីដំណើរការជាក់លាក់ ដូចជា មជ្ឈត្តវិនិច្ឆ័យ (ឧបសម្ព័ន្ធ II)។

### 1.1.5 ការអនុម័ត និងការចូលជាធរមាន

ប្រជាជាតិសរុបចំនួន១០៣ បានបោះឆ្នោតអនុម័តយល់ព្រមលើ UNWC នៅឆ្នាំ ១៩៩៧ និងប្រជាជាតិចំនួន៣ បានប្រឆាំងនឹងអនុសញ្ញានេះ (ចិន ប៊ុយរ៉ាន់ឌី និងតួរគី) និងមានអនុប្បវាទចំនួន ២៧ ផងដែរ ហើយប្រទេសចំនួន៥២ ផ្សេងទៀតមិនបានចូលរួមក្នុងការបោះឆ្នោតទេ។ ជារួម កំណត់ត្រានៃការបោះឆ្នោតនេះមានសារៈសំខាន់ដែលវាបានបង្ហាញឱ្យឃើញនូវការគាំទ្រជាសកលស្ទើរឯកច្ឆន្ទរបស់ប្រទេសដែលបានបោះឆ្នោតទាំងនោះ។

ទាក់ទងនឹងប្រទេសតាមដងទន្លេមេគង្គ មានចំណុចពីរគួរកត់សម្គាល់៖ ប្រទេសចិនបានបោះឆ្នោតប្រឆាំងការអនុម័តយល់ព្រមលើអនុសញ្ញា UNWC ខណៈដែលប្រទេសតាមទន្លេមេគង្គក្រោមទាំងអស់បានបោះឆ្នោតគាំទ្រការអនុម័តយល់ព្រមលើអនុសញ្ញា និងមានតែប្រទេសវៀតណាមមួយគត់ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ។

## 1.2 កិច្ចព្រមព្រៀងមេគង្គ៖ សារតា និងសេចក្តីសង្ខេប

### 1.2.1 វិវត្តន៍

កិច្ចសហប្រតិបត្តិការទឹកឆ្លងដែននៅក្នុងអាងទន្លេមេគង្គកើតមានឡើងនៅដើមឆ្នាំ ១៩៥០ តាមរយៈការបង្កើតគណៈកម្មការទន្លេមេគង្គដែលមានប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាមខាងត្បូង។ តាមប្រវត្តិសាស្ត្រមុនការចាប់ផ្តើមដំបូងនៃកិច្ចខិតខំប្រឹងប្រែងសហការខ្លាំងក្លារវាងប្រទេសតាមដងទន្លេ ដែលបាននាំឱ្យមានកិច្ចព្រមព្រៀងមេគង្គបែបទំនើបជាយថាហេតុ អន្តរកម្មរវាងប្រជាជនដែលរស់នៅតាមដងទន្លេ និងដៃទន្លេមានលក្ខណៈជាសង្គ្រាម និងជម្លោះ។ ការអនុម័តស្ថាពរលើកិច្ចព្រមព្រៀងមេគង្គ និងជាលទ្ធផលបង្កើតឡើងនូវគណៈកម្មការទន្លេមេគង្គ (MRC) ត្រូវបានប្រកាសឡើងជាការបើកទំព័រសករាជថ្មីនៅក្នុងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ និងជាការបង្កើត "របបច្បាប់អន្តរជាតិសម្រាប់ការចែករំលែកទឹក និងការធ្វើសេចក្តីសម្រេចលក្ខណៈសហប្រតិបត្តិការនៅក្នុងអាងទន្លេមេគង្គ" [3] នាពេលបច្ចុប្បន្ន។

### 1.2.2 សេចក្តីសង្ខេប

ដោយចែកចេញជាប្រាំមួយជំពូក ដែលមានប្រការសរុបចំនួន ៤២ មានគោលបំណងផ្សេងៗក្នុងការកំណត់តួនាទី និងទំនួលខុសត្រូវរបស់ប្រទេសតាមដងទន្លេ និងក្នុងអាងទន្លេ ហើយកិច្ចព្រមព្រៀងមេគង្គយកលក្ខណៈទូទៅនៃសន្ធិសញ្ញាមិនចងកាតព្វកិច្ច សម្រាប់ការអភិវឌ្ឍ គ្រប់គ្រង និងប្រើប្រាស់ធនធានទឹកទន្លេប្រកបដោយចីរភាព។ កាន់តែពិសេសទៅទៀត កិច្ចព្រមព្រៀងនេះដោះស្រាយបញ្ហាលំហូរជលសាស្ត្រផ្លាស់ប្តូរដែលអាចនាំឱ្យមានផលវិបាកដល់ការបង្វែរទឹកអន្តរអាង និងក្នុងអាង និងទំនប់ស្តុកធំៗ។

### 1.2.3 គោលការណ៍

ដោយផ្អែកយ៉ាងជាក់លាក់ទៅលើគោលការណ៍ច្បាប់នៃ "ការអភិវឌ្ឍប្រកបដោយចីរភាព" កិច្ចព្រមព្រៀងមេគង្គចែងថា សមាជិកទាំងអស់យល់ព្រមសហការក្នុងការគ្រប់គ្រង ប្រើប្រាស់ និងអភិរក្សទឹក និងធនធានពាក់ព័ន្ធនៅក្នុងអាងទន្លេមេគង្គ។ ជាមួយនឹង "ស្មារតីមេគង្គ" ដែលមិនត្រឹមតែគាំទ្រដល់ការបង្កើតកិច្ចព្រមព្រៀងប៉ុណ្ណោះទេ តែថែមទាំងត្រូវបានប្រើប្រាស់ក្នុងពេលអនុម័តកិច្ចព្រមព្រៀងផងដែរ គោលការណ៍កិច្ចសហប្រតិបត្តិការលើធនធានទឹករួមគ្នាមានលក្ខណៈជាក់ស្តែងបំផុតទាំងក្នុងអត្ថបទនៃកិច្ចព្រមព្រៀងមេគង្គ ក៏ដូចជាតំណាងឱ្យស្ថាប័នតាមរយៈគណៈកម្មការទន្លេមេគង្គ (MRC)។

### 1.2.4 នីតិវិធី

នីតិវិធីមានការទទួលស្គាល់មួយចំនួននៃច្បាប់ទឹកអន្តរជាតិ ដូចជា ការជូនដំណឹង និងពិគ្រោះយោបល់ជាមុនទាក់ទងនឹងការបង្វែរទឹកអន្តរអាងនៅរដូវវស្សា និងការបង្វែរទឹកក្នុងអាងនៅរដូវប្រាំង (ប្រការ ៥) ត្រូវបានប្រតិបត្តិដូចដែលមាននៅក្នុងអត្ថបទនៃកិច្ចព្រមព្រៀង។ ទោះបីជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិចម្បងទាក់ទងដោយផ្ទាល់ទៅនឹងការរៀបចំ និងមុខងារស្ថាប័នរបស់គណៈកម្មការទន្លេមេគង្គ

[3] Hirsch, 1999, p. 406-407.

(MRC) គឺការដោះស្រាយជម្លោះ (មាត្រា ៣៤-៣៥)។ នីតិវិធីជាច្រើនពង្រីកវិសាលភាពសម្រាប់ការអភិវឌ្ឍ អនុស្សរណៈ និងគោលការណ៍ណែនាំលម្អិតតែមិនចងកាតព្វកិច្ច ដោយគណៈកម្មការទន្លេមេគង្គ (MRC) និងអង្គភាពបច្ចេកទេសរបស់ខ្លួន។

### 1.2.5 ការអនុម័ត និងការចូលជាធរមាន

ដោយចូលជាធរមាននៅឆ្នាំ ១៩៩៥ កិច្ចព្រមព្រៀងមេគង្គត្រូវបានអនុម័តដោយប្រទេសតាមដងទន្លេមេគង្គក្រោម ដូចជា ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម និងត្រូវបានអមដោយការបង្កើតស្ថាប័នអាងអន្តររដ្ឋាភិបាលដ៏រឹងមាំមួយគឺ គណៈកម្មការទន្លេមេគង្គ (MRC)។ សន្ធិសញ្ញាត្រូវបានបង្កើតឡើងលើកដំបូងជា "ក្របខណ្ឌស្ថាប័នចម្រើនបំផុតសម្រាប់ការគ្រប់គ្រងផ្លូវទឹកអន្តរជាតិ "[4] សម្រាប់ថេរវេលារបស់ខ្លួន និងត្រូវបានលើកសរសើរតាមរយៈគណៈកម្មការទន្លេមេគង្គ (MRC) ជា "គំរូសម្រាប់ពិភពលោក"[5]។ កិច្ចព្រមព្រៀងមេគង្គ និងគណៈកម្មការទន្លេមអេគង្គ (MRC) តាមរយៈ "ស្មារតីមេគង្គ" របស់ខ្លួន ដែលមានរយៈពេល ២០ ឆ្នាំ គឺជាការគួរឱ្យកោតសរសើរ និងជាបណ្តាំដ៏មានសារៈសំខាន់នៃការគ្រប់គ្រងទឹកឆ្លងដែនបែបសហប្រតិបត្តិការនៅក្នុងតំបន់។ ក៏ប៉ុន្តែ ការបដិសេធឥតឈប់ឈរពីសំណាក់ប្រទេសចិនក្នុងការក្លាយខ្លួនជាហត្ថលេខីនៅតែជាចំណុចមួយនៃតំណរភ្ជាប់ខ្វះការតិទៀនរបស់កិច្ចព្រមព្រៀងមេគង្គ។

[4] Bearden, 2010, p. 798
[5] Ibid., p. 803

### 1.3 គណៈកម្មការទន្លេមេគង្គ (MRC)

#### 1.3.1 សេចក្ដីសង្ខេប

គណៈកម្មការទន្លេមេគង្គ (MRC) ជាស្ថាប័នចម្បងសម្រាប់ការសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងការអនុវត្តកិច្ចព្រមព្រៀងមេគង្គរវាងប្រទេសជាសមាជិកនៃកិច្ចព្រមព្រៀង។ ប្រទេសចំនួនបួនដែលជាភាគីនៃកិច្ចព្រមព្រៀងទន្លេមេគង្គមានដូចជា ប្រទេសកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាម រួមទាំងប្រទេសស្ថាបនិកដែលតំណាងដោយគណៈកម្មការទន្លេមេគង្គ (MRC) ផងដែរ។ ប្រទេសចិន និងប្រទេសភូមា មានឋានៈជាអ្នកអង្កេតការណ៍។

#### 1.3.2 រចនាសម្ព័ន្ធ និងអាណត្តិ

និយាយពីរចនាសម្ព័ន្ធ គណៈកម្មការទន្លេមេគង្គ (MRC) មានអង្គភាពអចិន្ត្រៃយ៍ចំនួនបី គឺៈ ក្រុមប្រឹក្សា គណៈកម្មការរួម និងលេខាធិការដ្ឋាន។

#### 1.3.3 មុខងារ

គណៈកម្មការទន្លេមេគង្គ (MRC) បំពេញមុខងារជាក់លាក់ស្របតាមអាណត្តិជួយសម្រួលទូទៅ និងសមាសធាតុរចនាសម្ព័ន្ធគន្លឹះរបស់ខ្លួន។ ជាពិសេស ទិដ្ឋភាពបច្ចេកទេស និងវិទ្យាសាស្ត្រនៃការងាររបស់គណៈកម្មការទន្លេមេគង្គ (MRC) បានទទួលការចាប់អារម្មណ៍ និងការផ្ដល់មូលនិធិជាច្រើនពីសំណាក់ម្ចាស់ជំនួយខាងក្រៅ។ គណៈកម្មការទន្លេមេគង្គ (MRC) បានចងក្រងមូលដ្ឋានទិន្នន័យយ៉ាងច្រើនមិនអាចកាត់ថ្លៃបាននៃព័ត៌មានទាក់ទងនឹងទិដ្ឋភាពគន្លឹះ ដូចជា ជលសាស្ត្រ ភូមិសាស្ត្រ និងជលផលសម្រាប់អាងទាំងមូលផង និងសម្រាប់ប្រទេស និងតំបន់ជាក់លាក់ផង។ ចាប់តាំងពីឆ្នាំ ១៩៩៥ មក ម្ចាស់ជំនួយបានវិនិយោគយ៉ាងច្រើនទៅក្នុងការសិក្សាស្រាវជ្រាវជលផលដោយ លេខាធិការដ្ឋាននៃគណៈកម្មការទន្លេមេគង្គ (MRC)។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបញ្ជាក់អំពីតម្លៃ និងផលិតភាពដ៏មហាសាលនៃជលផលប្រមូលបាននៅទន្លេមេគង្គ ដែលអាស្រ័យលើការថែរក្សាបូរណភាពអេកូឡូស៊ីនៃប្រព័ន្ធទន្លេមេគង្គ។

តាំងពីការចាប់ផ្ដើមរបស់ខ្លួន បញ្ហាចម្រូងចម្រាស់អំពីទំនប់វារីអគ្គិសនី ជាពិសេសទំនប់នៅតាមដងទន្លេមេគង្គ បានស្ថិតនៅចំណុចស្នូលនៃការងាររបស់ MRC។ ចំពោះបញ្ហានេះ MRC បានបំពេញមុខងារផ្សេងៗក្នុងកិច្ចការសម្រួល និងធ្វើគោលនយោបាយនៅវង្វង់ដែនកំណត់នៃអាណត្តិរបស់ខ្លួន ដើម្បីជូនដំណឹង និងធ្វើឱ្យប្រសើរឡើងនូវដំណើរការវិភាគពីផលប៉ះពាល់ ការចចារ និងការធ្វើសេចក្ដីសម្រេចចិត្ត ឧបករណ៍ និងមូលដ្ឋានចំណេះដឹងនៃប្រទេសសមាជិករបស់ខ្លួនស្ដីពីគម្រោងវារីអគ្គិសនីខ្នាតធំ។

*ការដោះស្រាយជម្លោះ*

យោងតាមមាត្រា ៣៤ និង៣៥ នៃកិច្ចព្រមព្រៀងមេគង្គ បញ្ហាដែលមិនអាចត្រូវបានដោះស្រាយដោយការសហការចចារ និងដែលអាចនាំទៅដល់ភាពទ័លច្រក ឬ ជម្លោះរវាងសមាជិករបស់ខ្លួន ត្រូវបានបញ្ជូនទៅ MRC សម្រាប់ស្វែងរកដំណោះស្រាយ។ តាមនីតិក្រម ជម្លោះបែបនេះត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សា ឬរវាងអង្គប្រជុំក្រុមប្រឹក្សាសាមញ្ញដឹកនាំដោយគណៈកម្មការរួម (មាត្រា ១៤ (F))។ ទោះបីជាយ៉ាងណាក៏ដោយ ការខ្វះនីតិវិធីលម្អិតដើម្បីដឹកនាំដំណើរការដោះស្រាយជម្លោះរវាងប្រទេសសមាជិក និងអវត្តមាននៃយុត្តាធិការពេញសមត្ថកិច្ចលើការគ្រប់គ្រងអាងទន្លេ មានន័យថា តួនាទីរបស់ MRC ជា "តួនាទីចម្បងនៃសន្ទានការី និងអ្នកសម្របសម្រួលនៃកិច្ចពិភាក្សារវាងតំណាងរបស់រដ្ឋាភិបាលជាតិនានា" [6]។

*ការអភិវឌ្ឍនីតិវិធី និងគោលការណ៍ណែនាំ*

នៅចន្លោះឆ្នាំ ២០០០ និង ២០០៨ MRC បានចងក្រងនីតិវិធីមួយកំប្លេ ដើម្បីបំពេញបន្ថែមលើបទប្បញ្ញត្តិទូទៅនៅក្នុងកិច្ចព្រមព្រៀងមេគង្គៈ នីតិវិធីសម្រាប់ការផ្លោះប្ដូរ និងចែករំលែកទិន្នន័យ និងព័ត៌មាន ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០១ នីតិវិធីសម្រាប់ការត្រួតពិនិត្យការប្រើប្រាស់ទឹក ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០៣ នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀងដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០៣ នីតិវិធីសម្រាប់ការថែរក្សាលំហូរទឹកនៅក្នុងទន្លេមេ ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០០៦ និងនីតិវិធី

[6] Rieu-Clarke &Gooch, op.cit. p. 217

សម្រាប់គុណភាពទឹក ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១១។ គ្រប់ឃុតនៃនីតិវិធីទាំងអស់ត្រូវបានអមជាបន្តបន្ទាប់ដោយគោលការណ៍ណែនាំបច្ចេកទេសរបស់ MRC សម្រាប់ការអនុវត្ត។ នៅពេលនីតិវិធីជាក់លាក់ទាំងនេះត្រូវបានតម្រូវឱ្យអភិវឌ្ឍយោងតាមមាត្រា ៥ ៦ និង ២៦ នៃកិច្ចព្រមព្រៀង នីតិវិធីទាំងនោះនៅក្រៅពីលិខិតូបករណ៍របស់សន្ធិសញ្ញា ដូច្នេះមានលក្ខណៈមិនចងកាតព្វកិច្ច។ នីតិវិធីសម្រាប់ក្របខណ្ឌនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNCPA) នឹងត្រូវប្រៀបធៀបជាមួយ UNWC នៅក្នុងផ្នែកទី ៧ ខាងក្រោម។

#### 1.3.4 ឋាន:

ការរិះគន់របស់ខ្លួនអះអាងថា តួនាទី រចនាសម្ព័ន្ធ និងអំណាចរបស់ MRC បិទបាំងចន្លោះប្រហោងក្នុងការគ្រប់គ្រងទន្លេមេ និងដៃទន្លេមេគង្គ។ ការកំណត់ជាមូលដ្ឋានខ្ពស់បំផុតរបស់ MRC ត្រូវបានចែករំលែកជាមួយកិច្ចព្រមព្រៀងមេគង្គ៖ ការដែលប្រទេសចិន និងប្រទេសភូមាបានបដិសេធការចូលរួម។ នេះគឺជាការបង្ការកុំឱ្យ MRC គ្រប់គ្រងអាងទន្លេមេគង្គទាំងមូល។

## 2 UNWC និងកិច្ចព្រមព្រៀងមេគង្គ៖ ការវិភាគច្បាប់ប្រៀបធៀប

### 2.1 វិសាលភាព និងនិយមន័យ

<table>
<tr><th>UNWC</th><th>កិច្ចព្រមព្រៀងមេគង្គ</th></tr>
<tr><td>UNWC អនុវត្តចំពោះការប្រើប្រាស់ផ្លូវទឹកអន្តរជាតិ ក្រៅពីនាវាចរណ៍ និងវិធានការសម្រាប់គោលបំណង "ការពារ អភិរក្ស និងគ្រប់គ្រងទាក់ទងនឹងការប្រើប្រាស់ផ្លូវទឹកទាំងនោះ និងទឹករបស់វា" (មាត្រា ១(១))។ ការប្រើប្រាស់ផ្លូវទឹកដែលប៉ះពាល់ដល់នាវាចរណ៍ ឬដែលត្រូវបានប៉ះពាល់ដោយនាវាចរណ៍ ក៏ធ្លាក់ទៅក្នុងវិសាលភាពនៃអនុសញ្ញានេះដែរ។<br>យោងតាម UNWC "ផ្លូវទឹក" គឺជាប្រព័ន្ធទន្លេមួយដែលរួមបញ្ចូលទាំងទឹកលើផ្ទៃដី ដែលភ្ជាប់ដៃទន្លេ និងទឹកក្រោមដីដែលហូរឆ្ពោះទៅកាន់ទីបញ្ចប់រួមមួយ (មាត្រា ២(ក))។ "ផ្លូវទឹកអន្តរជាតិ" គឺជាផ្លូវទឹកមួយដែលធ្លាក់ទៅក្នុង ឬជាប់ជាមួយព្រំដែននៃប្រទេសពីរ ឬច្រើន (មាត្រា ២(ខ))។ "ប្រទេសនៃផ្លូវទឹក" គឺជា "ប្រទេសភាគីនៃអនុសញ្ញានេះ ដែលនៅក្នុងដែនដីនៃប្រទេសនោះមានផ្លូវទឹកអន្តរជាតិមួយផ្នែកស្ថិតនៅ ឬជាភាគីដែលជាអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ដែលនៅក្នុងដែនដីរបស់ប្រទេសសមាជិកមួយ ឬច្រើននៃអង្គការនោះ មានផ្លូវទឹកអន្តរជាតិមួយផ្នែកស្ថិតនៅ" (ប្រការ 2 (គ)) និង "អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់" គឺជាស្ថាប័នអន្តររដ្ឋាភិបាលថ្នាក់តំបន់ដែលធ្វើប្រតិបត្តិការក្នុងគោលបំណងនៃសមាហរណកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច (ប្រការ 2 (ឃ))។</td><td>ជាជាង "ផ្លូវទឹក" កិច្ចព្រមព្រៀងទន្លេមេគង្គលើកឡើងនូវសញ្ញាណនៃពាក្យ "អាង" តាមរយៈអត្ថបទរបស់កិច្ចព្រមព្រៀង ប៉ុន្តែមិនកំណត់និយមន័យច្បាស់លាស់ដល់ពាក្យនេះទេ។ សន្ធិសញ្ញាប្រើពាក្យនេះនៅក្នុងបរិបទផ្សេងៗគ្នា ជាញឹកញាប់បំផុតថា "អាង" ទន្លេមេគង្គ ក៏ដូចជា "អាងទន្លេ" "កម្រិតអាង" "អាងធំ" និង "ប្រព័ន្ធទន្លេ" ពាសពេញ ប៉ុន្តែកិច្ចព្រមព្រៀងមិនអាចកំណត់និយមន័យដល់ពាក្យទាំងអស់នេះ។<br>លើសពីនេះទៀត កិច្ចព្រមព្រៀងទន្លេមេគង្គលើកឡើងនូវពាក្យ "ដៃ" នេះក៏ត្រូវបានកំណត់និយមន័យតែក្នុងនីតិវិធីខាងក្រៅនៅឡើយ ដែលមិនចងកាតព្វកិច្ចតាមច្បាប់។ ការចែកដាច់រវាង "ទន្លេមេ" និង "ដៃទន្លេ" នៅក្នុងអត្ថបទ ដោយគ្មានកំណត់ភាពខុសគ្នារវាងពាក្យទាំងនេះមានហេតុផលផ្លូវច្បាប់សំខាន់សម្រាប់នីតិវិធីនៃការជូនដំណឹង និងពិគ្រោះយោបល់ជាមុនសម្រាប់គម្រោងវារីអគ្គិសនីដែលត្រូវបានត្រួតពិនិត្យទាក់ទងនឹងដំណើរការមិនចងកាតព្វកិច្ចមួយចំនួនក្នុងក្របខណ្ឌនៃ PNPCA ។</td></tr>
<tr><td colspan="2">សមិតភាព (ភាពស្របគ្នា) និងចន្លោះប្រហោង<br>UNWC បោះជំហានទៅមុខខ្លាំងជាងកិច្ចព្រមព្រៀងមេគង្គ ទាំងខាងវិសាលភាពភូមិសាស្ត្រ និងមុខងារ។ ទីមួយ ប្រតិបត្តិការទាំងជាមួយទឹកលើផ្ទៃដី និងទឹកក្រោមដី (ទោះបីជាវាជាប់ផ្ទាល់នឹងវដ្តជលសាស្ត្រនៃទឹកលើផ្ទៃដីក៏ដោយ) ដោយដាក់វាជារបស់រួមបញ្ចូលតែមួយ។ UNWC អនុម័ត អភិក្រមរួម និងសន្ទានកម្មសម្រាប់ការគ្រប់គ្រងទឹកសាប តាមរយៈការធ្វើសមាហរណកម្មធនធានទឹកក្រោមដីដែលជាប់ និងប៉ះ លំហូរទឹកលើផ្ទៃដី ព្រមទាំងបរិស្ថានលើគោកដទៃទៀត។<br>ម្យ៉ាងវិញទៀត UNWC មិនបែងចែករវាងទន្លេមេ និងដៃទន្លេ ដែលចាត់ទុកវាជារបស់តែមួយដោយស្របច្បាប់។ ផ្ទុយទៅវិញ កិច្ចព្រមព្រៀងមេគង្គមិនលើកឡើងអំពីទឹកក្រោមដីនៅក្នុងអត្ថបទរបស់ខ្លួនឡើយ។ កិច្ចព្រមព្រៀងមេគង្គក៏បានបញ្ចូលនិយមន័យ និងការប្រើប្រាស់ដែលបានស្នើមួយចំនួនទាក់ទងតែនឹងការបង្វែរទឹកចូលអាងនៅរដូវវស្សាពីទន្លេមេ លើកលែងការប្រើប្រាស់ទឹកលក្ខណៈគ្រួសារ និងតិចតួច ដែលមិនមានផលប៉ះពាល់ខ្លាំងដល់លំហូរទន្លេមេ ដែលមិនមែនដៃទន្លេ។ វាមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងទន្លេ និងអាងទាំងមូល ពីព្រោះ បើទោះបីជាអត្ថបទនៃកិច្ចព្រមព្រៀងបែងចែករវាងទន្លេមេ និងដៃទន្លេសម្រាប់គោលបំណងនៃការគ្រប់គ្រងក៏ដោយ ក៏នៅខ្វះគោលការណ៍ និងយន្តការណ៍ច្បាប់ជាក់លាក់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍផ្លូវទឹក និងដៃទន្លេ។</td></tr>
</table>

## 2.2 គោលការណ៍សំខាន់៖ ការអភិវឌ្ឍប្រកបដោយចីរភាព

<table>
<tr><th>UNWC</th><th>កិច្ចព្រមព្រៀងមេគង្គ</th></tr>
<tr><td>UNWC យកភាពជាក់លាក់ជាគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងអត្ថបទរបស់ខ្លួន។ មាត្រា ២៤ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងផ្លូវទឹកអន្តរជាតិ ចែងថា "តាមសំណើរបស់ប្រទេសនៃផ្លូវទឹក ប្រទេសនៃផ្លូវទឹកត្រូវធ្វើការពិគ្រោះយោបល់ទាក់ទងនឹងការគ្រប់គ្រងផ្លូវទឹកអន្តរជាតិ ដែលអាចរួមមានទាំងការបង្កើតយន្តការណ៍គ្រប់គ្រងរួម"(មាត្រា ២៤ (១) និង ២៤ (២) បន្ទាប់មកប្រកាសថា "សម្រាប់គោលបំណងនៃប្រការនេះ "ការគ្រប់គ្រង" សំដៅជាពិសេសទៅដល់៖ (ក) ការធ្វើផែនការអភិវឌ្ឍប្រកបដោយចីរភាពនៃផ្លូវទឹកអន្តរជាតិ និងការផ្តត់ផ្គង់សម្រាប់ការអនុវត្តផែនការណាមួយដែលត្រូវបានអនុម័ត និង (ខ) ការលើកកម្ពស់ការប្រើប្រាស់សមហេតុផល និងត្រឹមត្រូវតាមលទ្ធភាព ការការពារ និងការត្រួតពិនិត្យផ្លូវទឹក"។ ចំពោះបញ្ហានេះ UNWC ចែងចំណុចយោងតាមច្បាប់សម្រាប់ការអនុវត្ត និងប្រើប្រាស់ជាក់ស្តែងនូវគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព ពីព្រោះវាទាក់ទងនឹងការធ្វើផែនការ និងការអនុម័តផែនការក្នុងការគ្រប់គ្រងទាំងមូលលើផ្លូវទឹកអន្តរជាតិ។</td><td>ក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គ ការអភិវឌ្ឍប្រកបដោយចីរភាពត្រូវបានបកស្រាយថាជា "តុល្យភាពមួយដែលសម្រេចបានរវាងការថែរក្សាគុណភាពសមស្រប និងនិងការរក្សាគុណភាពល្អនៃទឹក" ។ ជាវិបាកមួយ កិច្ចព្រមព្រៀងទន្លេមេគង្គបញ្ចូលបទប្បញ្ញត្តិគន្លឹះនានាដែលមានមុខងារជាយន្តការណ៍ច្បាប់សម្រាប់សម្រេចបានតុល្យភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព៖ ការការពារបរិស្ថាន (មាត្រា ៣) ការប្រើប្រាស់ប្រកបដោយសមភាព និងសមស្រប (មាត្រា ៥) ការថែរក្សាលំហូរ (មាត្រា ៦) និងកាតព្វកិច្ចសម្រាប់ប្រទេសដែលបង្កការប៉ះពាល់ខ្លាំងដល់ប្រទេសដទៃ ក្នុងការកាត់បន្ថយភ្លាមនូវការប្រើប្រាស់ទន្លេដែលបង្កផលប៉ះពាល់រហូតដល់កម្រិតនៃផលប៉ះពាល់ដែលបានកំណត់ (មាត្រា៧)។ ដោយធ្វើឡើងរួមគ្នា បទប្បញ្ញត្តិគោលនៃកិច្ចព្រមព្រៀងទន្លេមេគង្គត្រូវប្រតិបត្តិរួមគ្នា ដើម្បីសម្រេចបាននូវការអភិវឌ្ឍទឹកប្រកបដោយចីរភាព ឬតុល្យភាពដែលសម្រេចបានរវាងចំនួនសមរម្យ និងគុណភាពល្អនៃទឹក។</td></tr>
<tr><td colspan="2">សមិតភាព (ភាពស្របគ្នា) និងចន្លោះប្រហោង<br>នៅពេល UNWC និងកិច្ចព្រមព្រៀងមេគង្គខុសគ្នាខាងភាពរឹងមាំ និងភាពច្បាស់លាស់នៃបទប្បញ្ញត្តិច្បាប់របស់ខ្លួន ដើម្បីគាំទ្រដល់ការអភិវឌ្ឍទឹកប្រកបដោយចីរភាព អនុសញ្ញា និងកិច្ចព្រមព្រៀងនេះមានសមិតភាព (ភាពស្របគ្នា) ក្នុងទិដ្ឋភាពខ្លះ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលភាសាគោលនៃកិច្ចព្រមព្រៀងមេគង្គបានបកស្រាយទាក់ទងនឹងគោលការណ៍ចីរភាព គោលការណ៍ណែនាំ និងគោលដៅនៅក្នុងអត្ថបទមានភាពស្រពិចស្រពិលខ្លាំង។ ជាលទ្ធផល វាពិបាកក្នុងការធានាការអនុវត្តន៍ងាយស្រួលតាមច្បាប់ដោយស្មើភាពគ្នា និងមានការព្រមព្រៀងនៃបទប្បញ្ញត្តិស្នូលរបស់កិច្ចព្រមព្រៀងមេគង្គសម្រាប់ការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ ម្យ៉ាងវិញទៀត UNWC ចែងអំពីចំណុចយោងជាក់លាក់តាមច្បាប់សម្រាប់ការអនុវត្តគោលការណ៍នៃការអភិវឌ្ឍ ប្រកបដោយចីរភាព ក្នុងការគ្រប់គ្រងផ្លូវទឹកអន្តរជាតិ។</td></tr>
</table>

## 2.3 គោលការណ៍សំខាន់៖ ការប្រើប្រាស់ដោយស្មើភាព និងសមហេតុផល

<table>
<tr>
<th>UNWC</th>
<th>កិច្ចព្រមព្រៀងមេគង្គ</th>
</tr>
<tr>
<td>ក្នុងបរិបទនៃផ្លូវទឹកអន្តរជាតិ អ្នកជំនាញច្បាប់បានកំណត់ថា ពាក្យ "ដោយស្មើភាព" នៅក្នុង UNWC និងច្បាប់អន្តរជាតិតាមប្រពៃណី អាចត្រូវបានយល់អត្ថន័យថា "សិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ទឹកសម្រាប់គោលបំណងមានប្រយោជន៍ ជាជាងការចែកជាភាគស្មើគ្នា"។ UNWC មិនកំណត់ថា តើ "ដោយស្មើភាព និងសមហេតុផល" មានន័យយ៉ាងដូចម្ដេចនៅក្នុងពាក្យច្បាប់ជាក់លាក់នោះទេ ជំនួសមកវិញ អនុសញ្ញានេះចែងអំពីការដឹកនាំថាតើការប្រើប្រាស់ដោយស្មើភាព និងសមហេតុផលត្រូវបានកំណត់យ៉ាងដូចម្ដេចនៅក្នុងអត្ថន័យងាយស្រួល ដោយការរៀបរាប់សូចនាករចម្បងៗដែលត្រូវគិតពិចារណា នៅពេលវាយតម្លៃថាតើការប្រើប្រាស់ថ្មី ឬកើនឡើងមានសង្គតភាពជាមួយជាមួយគោលការណ៍នៅក្នុងមាត្រា ៥ និង៦។</td>
<td>កិច្ចព្រមព្រៀងទន្លេមេគង្គអាចត្រូវបានបកស្រាយជាការធានាឧត្ដមភាពច្បាប់លើគោលការណ៍នៃការប្រើប្រាស់ដោយស្មើភាព និងសមហេតុផល ទាក់ទងនឹងគោលការណ៍ច្បាប់ទឹកអន្តរជាតិផ្សេងទៀត ដែលមានខ្លឹមសារក្នុងអត្ថបទនៃកិច្ចព្រមព្រៀង និងក្នុងការរក្សាឋានៈនៃកិច្ចព្រមព្រៀងតាមច្បាប់អន្តរជាតិតាមប្រពៃណី។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចព្រមព្រៀងក៏បែងចែកផងដែររវាងការប្រើប្រាស់នៅរដូវវស្សា និងរដូវប្រាំង ដែលមិនមែនជាដំណោះស្រាយដែលត្រូវបានទទួលស្គាល់ជាទូទៅ សម្រាប់ការប្រើប្រាស់ដោយស្មើភាព និងសមហេតុផល។ម្យ៉ាងវិញទៀត ភាពខុសគ្នារវាងខ្សែទឹកចម្បង និងដៃទន្លេក្នុងមាត្រា ៥ (ក) និង ៦ និងក្នុងអត្ថបទទាំងមូល បានបកស្រាយថា គោលការណ៍ផ្សេងគ្នាត្រូវបានអនុវត្តចំពោះខ្សែទឹកខាងលើនៃទន្លេ ប៉ុន្តែ មិនមែនដៃទន្លេឡើយ។ ជាលទ្ធផល ការអនុវត្តន៍ច្បាប់ប្រតិបត្តិការជាក់ស្ដែងនៃការប្រើប្រាស់ដោយស្មើភាព និងសមហេតុផលក្រោមកិច្ចព្រមព្រៀងទន្លេមេគង្គគឺពុំមានវិសាលភាពទូទាំងតំបន់អាងទន្លេឡើយ។</td>
</tr>
<tr>
<th colspan="2">សមិតភាព</th>
</tr>
<tr>
<td colspan="2">UNWC រួមបញ្ចូលកត្តាពាក់ព័ន្ធដើម្បីកំណត់នូវការប្រើប្រាស់ដោយស្មើភាព និងសមហេតុផល (មាត្រា ៥ និង៦)។ កិច្ចព្រមព្រៀងមេគង្គគាំទ្រនូវការប្រើប្រាស់ដោយស្មើភាព និងសមហេតុផលជាគោលការណ៍ ប៉ុន្តែការអនុវត្តន៍ជាក់ស្ដែងបានបែងចែកភាពខុសប្លែកគ្នារវាងខ្សែទឹកចម្បង និងដៃទន្លេ ព្រមទាំងលំហូរក្នុងរដូវវស្សា និងប្រាំង។ មានន័យថា វិសាលភាពស្របច្បាប់ និងការអនុវត្តន៍ប្រតិបត្តិការជាក់ស្ដែងខុសគ្នានៃការប្រើប្រាស់ដោយស្មើភាព និងសមហេតុផល គឺត្រូវបានដាក់កំហិតជាច្រើន បើប្រៀបធៀបនឹង UNWC និងតាមរយៈការជាប់ពាក់ព័ន្ធទៅនឹងច្បាប់អន្តរជាតិជាប្រពៃណី។<br>ទោះបីជាយ៉ាងណាក៏ដោយ វាមានទឡ្ហីករណ៍ថា ក្រោមច្បាប់អន្តរជាតិជាប្រពៃណី និងអ្វីផ្សេងទៀត UNWC ដែលជាការតាក់តែងត្រូវបានទទួលស្គាល់ជាទូទៅ គោលការណ៍នៃការប្រើប្រាស់ដោយស្មើភាព និងសមហេតុផលអាចអនុវត្តចំពោះខ្សែទឹកចម្បង និងដៃទន្លេក្នុងវិធានការស្មើភាពបានក្នុងអំឡុងពេលរដូវវស្សា និងរដូវប្រាំង។ ក្រោមការបកស្រាយនេះ វាបង្ហាញថា ប្រទេសក្នុងតំបន់អាងទន្លេមេគង្គទាំងអស់ មិនត្រឹមតែប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀងឡើយ ត្រូវមានកាតព្វកិច្ចអនុវត្តគោលការណ៍នេះទាំងក្នុងខ្សែទឹកចម្បង និងដៃទន្លេ។ ដោយពិចារណាទៅលើភាពស្របគ្នាទូទៅ កិច្ចព្រមព្រៀងមេគង្គ ព្រមទាំងនីតិវិធី និងការណែនាំដែលពាក់ព័ន្ធនឹងទទួលប្រយោជន៍យ៉ាងច្បាស់ដែលអាចចែងក្នុង UNWC មាត្រា ៦ កត្តារួមចំណែកក្នុងការកំណត់ការអនុវត្តន៍ច្បាប់។</td>
</tr>
</table>

## 2.4 គោលការណ៍ជាក់លាក់៖ កាតព្វកិច្ចមិនបង្កព្យសនកម្ម (អន្តរាយ) ធ្ងន់ធ្ងរ (និងភារកិច្ចពាក់ព័ន្ធក្នុងការការពារប្រព័ន្ធអេកូឡូស៊ី)

<table>
<tr><th>UNWC</th><th>កិច្ចព្រមព្រៀងមេគង្គ</th></tr>
<tr><td>មាត្រា ៧ នៃ UNWC រៀបរាប់យ៉ាងលម្អិតអំពីកាតព្វកិច្ចទូទៅមិនបង្កព្យសនកម្មធ្ងន់ធ្ងរ។ វាចាប់ផ្ដើមដំបូងដោយចែងថា "ប្រទេសផ្លូវទឹកដែលកំពុងប្រើប្រាស់ផ្លូវទឹកអន្តរជាតិក្នុងដែនដីរបស់ខ្លួនត្រូវចាត់វិធានការសមស្របដើម្បីទប់ស្កាត់ការបង្កព្យសនកម្មធ្ងន់ធ្ងរចំពោះផ្លូវទឹកនៃប្រទេសផ្សេងទៀត" មាត្រា ៧(១)។ ដោយពាក់ព័ន្ធផ្ទាល់នឹងកាតព្វកិច្ចទូទៅនេះ មាត្រា ៧(២) បន្តចែងថា "នៅពេលដែលព្យសនកម្មធ្ងន់ធ្ងរបានបង្កឡើងចំពោះប្រទេសផ្លូវទឹកផ្សេងទៀត ប្រទេសដែលបង្កព្យសនកម្មដែលស្ថិតក្នុងស្ថានភាពគ្មានការព្រមព្រៀងឱ្យប្រើប្រាស់ ត្រូវពិចារណាគ្រប់ជ្រុងជ្រោយចាត់វិធានការសមស្របទាំងឡាយតាមបទប្បញ្ញត្តិនៃមាត្រា ៥ និង ៦ ដោយមានការពិគ្រោះយោបល់ជាមួយនឹងប្រទេសរងគ្រោះ ដើម្បីបំបាត់ ឬកាត់បន្ថយព្យសនកម្មនោះ ហើយនៅពេលសមស្រប ត្រូវពិភាក្សាអំពីបញ្ហាសំណង"។ វាចែងច្បាស់ដោយយោងតាមពាក្យ "ពិចារណាគ្រប់ជ្រុងជ្រោយ" ដែលថា អ្នកឯកទេសច្បាប់ជាច្រើនចាត់ទុកថាជាការផ្ដល់ភាពល្អបំផុតផ្នែកច្បាប់ចុងក្រោយចំពោះគោលការណ៍នៃការប្រើប្រាស់ដោយស្មើភាព និងសមហេតុផលចំពោះកាតព្វកិច្ចមិនបង្កព្យសនកម្មធ្ងន់ធ្ងរ។ ប្រាកដណាស់ សេចក្ដីយោងដោយផ្ទាល់នេះ "ជាក់ស្ដែងអាចទទួលស្គាល់ថា វាអាចត្រូវបានបង្ហាញថាមានព្យសនកម្មធ្ងន់ធ្ងរកើតឡើង ប៉ុន្តែវាក៏អាចត្រូវបានបញ្ជាក់ថា ព្យសនកម្មនោះគឺស្មើភាព និងសមហេតុផល ប្រទេសមួយនោះត្រូវគោរពតាមច្បាប់អន្តរជាតិ" និងច្បាប់អន្តរជាតិជាប្រពៃណីផ្សេងទៀតដូចបានតាក់តែងក្នុង UNWC។</td><td>មាត្រា ៧ នៃកិច្ចព្រមព្រៀងមេគង្គកំណត់កាតព្វកិច្ចចំពោះប្រទេសជាសមាជិកថា៖ "ត្រូវខិតខំប្រឹងប្រែងជៀសវាង កាត់បន្ថយជាអប្បបរិមា និងបន្សាយផលប៉ះពាល់ដែលអាចបង្កឡើងចំពោះបរិស្ថាន ជាពិសេស បរិមាណ និងគុណភាពទឹក លក្ខខណ្ឌវារីជាតិ (ប្រព័ន្ធអេកូឡូស៊ី) និងតុល្យភាពបរិស្ថាននៃប្រព័ន្ធទន្លេពីការអភិវឌ្ឍ និងការប្រើប្រាស់នៃប្រភពទឹកអាងទន្លេមេគង្គ ឬការបង្ហូរទឹកកខ្វក់ និងការហូរត្រឡប់។" បទប្បញ្ញត្តិនេះបញ្ជាក់បន្ថែមទៀតថា "នៅពេលដែលប្រទេសមួយ ឬប្រទេសច្រើនត្រូវបានជូនដំណឹងអំពីភស្តុតាងត្រឹមត្រូវ និងមានប្រសិទ្ធភាពដែលបង្ហាញថាមានការប៉ះពាល់ជាក់ស្ដែងចំពោះប្រទេសនៅតាមដងទន្លេមួយ ឬច្រើនដែលកើតចេញពីការប្រើប្រាស់ និង/ឬការបង្ហូរទឹកទន្លេមេគង្គប្រទេសនោះ ឬប្រទេសទាំងនោះត្រូវបញ្ឈប់ករណីព្យសនកម្មដែលត្រូវបានចោទប្រកាន់នោះភ្លាមៗរហូតដល់ព្យសនកម្មនោះត្រូវបានកំណត់យោងតាមមាត្រា៨។" (មាត្រា ៧ កិច្ចព្រមព្រៀងមេគង្គ)។ ចំណុចមាត្រា ៧ កំណត់កាតព្វកិច្ចចំពោះប្រទេសជាសមាជិក MRC "ត្រូវខិតខំប្រឹងប្រែង" ដើម្បី ជៀសវាង បន្សាយ និងកាត់បន្ថយជាអប្បបរមានូវផលប៉ះពាល់ ចំណុចនេះគឺស្របតាមសមាសធាតុត្រួតពិនិត្យទំនួលខុសត្រូវនៃច្បាប់ប្រពៃណីអន្តរជាតិដែលបានចាត់ទុកថាជាការដាច់ដោយឡែកមួយ។ កាតព្វកិច្ចរបស់ប្រទេសជាសមាជិក MRC "ត្រូវជៀសវាង កាត់បន្ថយជាអប្បបរមា និងបន្សាយផលប៉ះពាល់" ដូចបានចែងក្នុងមាត្រា ៧ តំណាងនូវការយកចិត្តទុកដាក់កំណត់ភារកិច្ចមូលដ្ឋាន កុំឱ្យបង្កព្យសនកម្មធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិជាប្រពៃណី និងផ្សេងទៀតដូចមាននៅក្នុង UNWC។</td></tr>
<tr><td colspan="2">សមិតភាព<br>UNWC បង្កើតនូវកាតព្វកិច្ចដែលបានកំណត់យ៉ាងត្រឹមត្រូវដើម្បីចាត់វិធានការសមស្របទាំងអស់កុំឱ្យបង្កព្យសនកម្មធ្ងន់ធ្ងរក្នុងមាត្រា ៧។ មាត្រា ៧ នៃកិច្ចព្រមព្រៀងមេគង្គ ពុំបានកំណត់ពាក្យ និងឃ្លាចម្បងក្នុងភារកិច្ចនេះឡើយ ជំនួសដោយការយោង "ផលប៉ះពាល់" ដែលតម្រូវឱ្យប្រទេសដែលរងគ្រោះត្រូវផ្ដល់នូវភស្តុតាង "គ្រោះថ្នាក់ជាក់ស្ដែង"។ ពាក្យទាំងពីរនេះសុទ្ធសឹងស្ថិតក្នុងរបបច្បាប់បច្ចុប្បន្ន។ ទោះបីជាយ៉ាងណាក៏ដោយ វាអាចមានទឡ្ហីករណ៍ថា UNWC និងកិច្ចព្រមព្រៀងទន្លេមេគង្គមានធាតុច្បាប់មូលដ្ឋានរៀងៗខ្លួនយោងតាមច្បាប់អន្តរជាតិជាប្រពៃណី នៅក្នុងបទប្បញ្ញត្តិ មាត្រា៧ ដែលបានកំណត់កាតព្វកិច្ចចំពោះប្រទេសនានា មិនត្រូវបង្កព្យសនកម្មដល់ប្រទេសផ្លូវទឹកផ្សេងទៀតឡើយ ដែលនេះគឺជាភារកិច្ចនៃការថែរក្សា និងជាសមាសធាតុការទទួលខុសត្រូវ។</td></tr>
</table>

## 2.5 កាតព្វកិច្ចខាងនីតិវិធី៖ គោលការណ៍នៃកិច្ចសហប្រតិបត្តិការ និងការផ្លោះប្តូរព័ត៌មាន

<table>
<tr><th>UNWC</th><th>កិច្ចព្រមព្រៀងមេគង្គ</th></tr>
<tr><td>ភារកិច្ចសហការត្រូវបានរួមបញ្ចូលក្រោមមាត្រា ៨ នៃ UNWC ដែលកំណត់កាតព្វកិច្ចចំពោះប្រទេសផ្លូវទឹកត្រូវ "សហការផ្អែកលើសមភាពអធិបតេយ្យ បូរណភាពទឹកដី អត្ថប្រយោជន៍ទ្វេភាគី និងភាពស្មោះត្រង់ ដើម្បីទទួលបានការប្រើប្រាស់ល្អបំផុត និងការការពារគ្រប់គ្រាន់លើផ្លូវទឹកអន្តរជាតិ" (មាត្រា ៨(១))។</td><td>កិច្ចព្រមព្រៀងទន្លេមេគង្គមានចំណងជើងដែលជាគោលការណ៍នៃ "កិច្ចសហប្រតិបត្តិការ" ហើយកិច្ចសហប្រតិបត្តិការត្រូវបានប្រើប្រាស់ពេញអត្ថបទនៃកិច្ចព្រមព្រៀងទាំងមូល។ វាមិនបង្ហាញចេញនូវពាក្យកាតព្វកិច្ចជាក់លាក់ឡើយ ប៉ុន្តែគឺជាគោលការណ៍ដែលបង្កប់ន័យ។ វាមានសារៈសំខាន់ដែលថា កិច្ចព្រមព្រៀងទន្លេមេគង្គពុំមានយោងជាក់លាក់លើ ឬកាតព្វកិច្ចសម្រាប់ ការផ្លោះប្តូរព័ត៌មានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងទាំងមូលនៃទន្លេមេគង្គ និងដៃទន្លេរបស់វាទេ។</td></tr>
<tr><td colspan="2">ភាពស្របគ្នា<br>ទោះបីជាលិខិតុបករណ៍ទាំងពីរបង្ហាញយ៉ាងច្បាស់លាស់នូវគោលការណ៍នៃកិច្ចសហប្រតិបត្តិការរវាងប្រទេសផ្លូវទឹកនានា និងអ្វីផ្សេងទៀតរួមមាន តួនាទី និងភាពទាក់ទងជាមូលដ្ឋានក្នុងអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៃផ្លូវទឹកអន្តរជាតិក៏ដោយ ប៉ុន្តែមានតែ UNWC ប៉ុណ្ណោះដែលកំណត់កាតព្វកិច្ចចំពោះភាគីប្រទេសឱ្យធ្វើការសហការ។ ទោះបីជាមានយោងជាច្រើនចំពោះពាក្យ "កិច្ចសហ-ប្រតិបត្តិការ" ក្នុងខ្លឹមសារ និងចំណងជើងក៏ដោយ កិច្ចព្រមព្រៀងមេគង្គមិនបានដាក់កាតព្វកិច្ចទូទៅមួយចំពោះប្រទេសផ្លូវទឹកដើម្បីសហការដោយផ្អែកលើប្រយោជន៍ទ្វេភាគី និងភាពស្មោះត្រង់ឡើយ។<br>ដោយឡែក MRC មានតួនាទីសំខាន់យ៉ាងច្បាស់ក្នុងការគាំទ្រដំណើរការសហការ ហើយកិច្ចព្រមព្រៀងមេគង្គមានបទប្បញ្ញត្តិយ៉ាងលម្អិតក្នុងការគាំទ្រនេះ ខណៈដែល UNWC ដោយសារតែលក្ខណៈជាសកលរបស់ខ្លួន អាចត្រឹមតែបទប្បញ្ញត្តិជម្រុញឱ្យប្រទេសផ្លូវទឹកបង្កើតការរៀបចំស្ថាប័នជាក់លាក់។<br>យ៉ាងណាក៏ដោយ UNWC អាចទៅមុខឆ្ងាយជាងកិច្ចព្រមព្រៀងមេគង្គក្នុងការកំណត់នូវកាតព្វកិច្ចខាងនីតិវិធី និងយន្តការបង្កើតដែលពាក់ព័ន្ធនឹងភារកិច្ចដែលត្រូវសហការ រួមបញ្ចូលទាំង ព័ត៌មានទូទៅ និងការផ្លាស់ប្តូរទិន្នន័យរវាងប្រទេសផ្លូវទឹក។ បទប្បញ្ញត្តិទាំងនេះត្រូវបានពង្រឹងដោយបទប្បញ្ញត្តិ UNWC ផ្សេងទៀត ដែលបង្ហាញពីគោលការណ៍នៃ "កិច្ចសហប្រតិបត្តិការ" ក្នុង "ភាពស្មោះត្រង់"។ លទ្ធផលចុងក្រោយគឺ UNWC ពាក់ព័ន្ធទាំងស្រុងជាមួយនឹងការសម្រេចបាននូវកាតព្វកិច្ចនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសផ្លូវទឹក និងផ្តល់នូវកញ្ចប់សរុបនៃកាតព្វកិច្ច និងនីតិវិធីដើម្បីជួយប្រទេសនានាក្នុងការសម្រេចបាននូវគោលដៅ។</td></tr>
</table>

## 2.6 កាតព្វកិច្ចខាងនីតិវិធី៖ គោលការណ៍នៃការជូនដំណឹងជាមុន ការពិគ្រោះយោបល់ និងការចរចា (លើវិធានការដែលបានគ្រោងទុក)

<table>
<tr><th>UNWC</th><th>កិច្ចព្រមព្រៀងទន្លេមេគង្គ</th></tr>
<tr><td>មាត្រា ១១ នៃ UNWC កំណត់កាតព្វកិច្ចចំពោះប្រទេសនានាត្រូវះផ្លោះប្តូរព័ត៌មាន ពិភាក្សាជាមួយគ្នា និងប្រសិនបើចាំបាច់ ត្រូវចរចាលើប្រសិទ្ធភាពដែលអាចទៅរួចនៃវិធានការដែលបានគ្រោងទុកចំពោះលក្ខខណ្ឌនៃផ្លូវទឹកអន្តរជាតិ។ មាត្រា១៣ (ក) បង្ហាញថា ប្រទេសដែលផ្តល់ការជូនដំណឹងត្រូវអនុញ្ញាតរយៈពេល ៦ ខែសម្រាប់ប្រទេសដែលត្រូវទទួលបានជូនការដំណឹង ដើម្បីវាយតម្លៃព័ត៌មាននេះ ធ្វើការសិក្សារបស់គេ រួចឆ្លើយតបវិញជាចុងក្រោយ។ យោងតាមការពិគ្រោះយោបល់ និងការចរចា មាត្រា ១៧ (១) បង្ហាញថា នៅពេលប្រទេសជូនដំណឹងទំនាក់ទំនងតាមរយៈការឆ្លើយតបថា គេកំណត់វិធានការគ្រោងទុកគឺមិនស្របគ្នានឹងមាត្រា៥ និង/ឬ មាត្រា៧ នោះទាំងប្រទេសជូនដំណឹង និងប្រទេសដែលត្រូវបានការជូនដំណឹង ត្រូវភ្ជាប់កាតព្វកិច្ច "ធ្វើការពិគ្រោះយោបល់ និងប្រសិនបើចាំបាច់ ត្រូវធ្វើការចរចាជាមួយនឹងទស្សនៈដើម្បីឈានដល់ដំណោះស្រាយស្មើភាពសម្រាប់ស្ថានភាពនោះ។" ក្នុងករណីនេះ ប្រទេសទាំងអស់ត្រូវចូលរួមក្នុងការពិគ្រោះយោបល់ និងការចរចាណាមួយ "ដោយភាពស្មោះត្រង់ និងផ្តល់ការគោរពឱ្យបានសមស្របចំពោះសិទ្ធិ និងប្រយោជន៍ស្របច្បាប់នៃប្រទេសម្ខាងទៀត" (មាត្រា ១៧(២))។</td>
<td>កិច្ចព្រមព្រៀងទន្លេមេគង្គផ្តល់នូវការណែនាំទូទៅ និងបទបញ្ញានីតិវិធីភ្ជាប់កាតព្វកិច្ចសម្រាប់ការជូនដំណឹង និងការពិគ្រោះយោបល់ជាមុន។ វាមានលក្ខណៈខុសពីបទប្បញ្ញត្តិនៃ UNWC ដោយធ្វើការបែងចែករវាងខ្សែទឹកចម្បង និងដៃទន្លេ។<br>ករណីខ្សែទឹកចម្បង គូភាគីត្រូវបានភ្ជាប់កាតព្វកិច្ចក្រោម មាត្រា ៥ (ខ) ដោយត្រូវជូនដំណឹងទៅគណៈកម្មការចម្រុះពាក់ព័ន្ធនឹងការប្រើប្រាស់អាងទន្លេខាងក្នុងដែលបានស្នើឡើងក្នុងអំឡុងពេលរដូវវស្សា និងរដូវប្រាំង ដែលត្រូវមានការពិគ្រោះយោបល់ជាមុន។ មាត្រា ៥ (ក) ចែងបន្ថែមទៀតថា "ការប្រើប្រាស់អាងទន្លេខាងក្នុង និងការបង្វែរអាងទន្លេខាងក្នុងទៅដៃទន្លេ រួមបញ្ចូលទាំង ទន្លេសាប នឹងត្រូវជូនដំណឹងដល់គណៈកម្មការចម្រុះជាមុនផងដែរ។"<br>ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនិយមន័យពាក់ព័ន្ធនឹង "ការប្រើប្រាស់ក្នុងស្រុក និងតិចតួច មិនបង្កឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់លំហូរខ្សែទឹកចម្បងឡើយ" វាគឺជាការព្រមានយ៉ាងសំខាន់ ដោយហេតុថា "ការជូនដំណឹងអំពីការប្រើប្រាស់ដែលបានស្នើសុំដែលមានផលប៉ះពាល់ត្រឹមដៃទន្លេមេគង្គ គឺមិនត្រូវបានរាប់បញ្ចូលក្នុងកិច្ចព្រមព្រៀង។"</td></tr>
<tr><td colspan="2">សមិតភាព<br>និយាយអំពីកាតព្វកិច្ចទាំងមូលសម្រាប់ការជូនដំណឹង និងការពិគ្រោះយោបល់ជាមុន ភាពខុសប្លែកគ្នាសំខាន់រវាងលិខិតុបករណ៍ទាំងពីរ គឺ UNWC ពុំមានបែងចែករវាងខ្សែទឹកចម្បង និងដៃទន្លេនៃផ្លូវទឹកអន្តរជាតិក្នុងបរិបទនេះឡើយ ប៉ុន្តែកិច្ចព្រមព្រៀងមេគង្គបានកំណត់យ៉ាងច្បាស់លាស់ ហើយ "ការប្រើប្រាស់ក្នុងស្រុក និងតិចតួចនៃទឹក ដែលមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់លំហូរខ្សែទឹកចម្បង" មិនបានរួមបញ្ចូលឡើយ។<br>ទោះបីជាមានភាពខុសគ្នានៃការបែងចែកទាំងនេះក៏ដោយ លិខិតុបករណ៍ទាំងពីរបង្ហាញនូវសមិតភាពផ្នែកច្បាប់ជាមូលដ្ឋានតាំងពីដើម ដោយលិខិតុបករណ៍ទាំងពីរបានតាក់តែងបទប្បញ្ញត្តិដែលបង្កើតវោហារសាស្ត្រ និងភាសាសាមញ្ញនៃកាតព្វកិច្ចសម្រាប់ការជូនដំណឹង និងការពិគ្រោះយោបល់ជាមុនលើវិធានការដែលបានគ្រោងទុក។ UNWC ផ្តល់នូវភាពតឹងរឹងផ្នែកច្បាប់ ភាពច្បាស់លាស់ និងស្ថានភាពភ្ជាប់កាតព្វកិច្ចដែលបច្ចុប្បន្ននេះគឺខ្វះខាតក្នុងកិច្ចព្រមព្រៀងមេគង្គ។<br>ចុងក្រោយ តម្រូវការសម្រាប់នីតិវិធីលម្អិតបន្ថែមអាចត្រូវបានបំពេញដោយ UNWC ពីព្រោះ "បទបញ្ញាខាងនីតិវិធីផ្តល់នូវក្របខណ្ឌតម្លាភាពសម្រាប់ការអភិវឌ្ឍ និងគ្រប់គ្រងនៃការប្រើប្រាស់ផ្លាស់ប្តូរនៃផ្លូវទឹកចែករំលែក"។</td></tr>
</table>

## 2.7 កាតព្វកិច្ចខាងនីតិវិធី៖ នីតិវិធីនៃការដោះស្រាយវិវាទ

<table>
<tr><th>UNWC</th><th>កិច្ចព្រមព្រៀងមេគង្គ</th></tr>
<tr><td>មាត្រា ៣៣ នៃ UNWC ដែលគាំទ្រដោយឧបសម្ព័ន្ធតែមួយគត់នៃអត្ថបទក្នុងអនុសញ្ញា ផ្តល់នូវក្របខណ្ឌផ្លូវច្បាប់សម្រាប់ការដោះស្រាយវិវាទ។ មាត្រា ៣៣ (១) ចែងថា នៅពេលគ្មានកិច្ចព្រមព្រៀងដែលអាចអនុវត្តបាន ប្រសិនបើកើតមានវិវាទរវាងភាគីពីរ ឬច្រើនពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍នៃ UNWC នោះប្រទេសនានាមានកាតព្វកិច្ចត្រូវ “ស្វែងរកការដោះស្រាយនៃវិវាទនោះដោយសន្តិវិធី”។<br><br>ប្រទេសដែលជាភាគីនៃ UNWC ត្រូវភ្ជាប់កាតព្វកិច្ចដោយបទប្បញ្ញត្តិជាបន្តបន្ទាប់ក្រោមមាត្រា ៣៣។ មាត្រា ៣៣ (២) បង្ហាញថា ប្រសិនបើភាគីនៃវិវាទពុំអាចឈានដល់ការព្រមព្រៀងគ្នាតាមរយៈការចរចាដែលស្នើឡើងដោយភាគីមួយ (ឬភាគីច្រើន ក្នុងករណីមានភាគីច្រើន) នោះពួកគេអាច “ស្វែងរកការិយាល័យល្អ ឬស្នើសុំការសម្រុះសម្រួល ឬការផ្សះផ្សាដោយតតិយជន ឬក្នុងករណីសមស្រប ប្រើប្រាស់ស្ថាប័នផ្លូវទឹកចម្រុះដែលបានបង្កើតដោយពួកគេ ឬយល់ព្រមដាក់វិវាទទៅមជ្ឈត្តវិនិច្ឆ័យ ឬទៅតុលាការយុត្តិធម៌អន្តរជាតិ”។<br><br>ប្រការ ៣៣ (៣) ផ្តល់នូវពេលវេលា និងនីតិវិធីលម្អិត ដោយឡែកប្រសិនបើរយៈពេល ៦ ខែក្រោយពេលប្រទេសភាគីស្នើសុំការចរចា ភាគីនានានៃវិវាទមិនអាចដោះស្រាយតាមរយៈការចរចា ឬវិធីផ្សេងទៀតបាន នោះវិវាទត្រូវ "ដាក់ជូនស្ថាប័នស៊ើបអង្កេតយុត្តិធម៌តាមការស្នើសុំរបស់ភាគីណាមួយនៃវិវាទ តាមកថាខណ្ឌ ៤ ដល់ ៩ លើកលែងតែគូភាគីមានការព្រមព្រៀងគ្នាដោយឡែក”។ តួនាទីផ្លូវច្បាប់ និងភាពទាក់ទងគ្នានៃស្ថាប័នស៊ើបអង្កេតយុត្តិធម៌ក្នុងគ្រោងការណ៍ទាំងមូលនៃនីតិវិធីដោះស្រាយវិវាទនៃ UNWC មិនអាចកំណត់បាន ដោយសារវាមានលក្ខណៈប្លែកខុសពីកិច្ចព្រមព្រៀងក្របខណ្ឌនេះក្នុងដែននៃច្បាប់ស្តីពីទឹកអន្តរជាតិ និងកិច្ច-ព្រមព្រៀងអាងទន្លេ/ទន្លេឆ្លងដែន។ ម្យ៉ាងវិញទៀត ដោយពិចារណាទៅលើយន្តការដោះស្រាយវិវាទដែលមានចែងតាមរយៈមាត្រា ៣៣(២) វានៅតែជានីតិវិធី និងវេទិកាដែលមិនអាចចរចាបាន និងភ្ជាប់កាតព្វកិច្ចយ៉ាងពិតប្រាកដក្នុង UNWC។</td><td>អត្ថបទនៃកិច្ចព្រមព្រៀងទន្លេមេគង្គរួមបញ្ចូលទាំងបទប្បញ្ញត្តិដោះស្រាយវិវាទជាក់លាក់។ ប្រការ ៨ យោងតាម “ទំនួលខុសត្រូវរបស់ប្រទេសចំពោះការខូចខាត” បានចែងថា “នៅពេលផលប៉ះពាល់បង្កការខូចខាតជាក់ស្តែងចំពោះប្រទេសនៅតាមដងទន្លេមួយ ឬច្រើន ដែលកើតចេញពីការប្រើប្រាស់ និង/ឬការបង្ហូរចូលក្នុងទឹកទន្លេមេគង្គដោយប្រទេសនៅតាមដងទន្លេនានា ភាគីពាក់ព័ន្ធត្រូវកំណត់នូវកត្តាពាក់ព័ន្ធទាំងអស់ មូលហេតុ ទំហំនៃការខូចខាត និងទំនួលខុសត្រូវសម្រាប់ការខូចខាតដែលបង្កឡើងដោយប្រទេសនោះ ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិពាក់ព័ន្ធនឹងទំនួលខុសត្រូវរបស់ប្រទេស ហើយធ្វើការដោះស្រាយវិវាទដោយសន្តិវិធី និងតាមពេលវេលាដូចបានចែងក្នុងប្រការ ៣៤ និង ៣៥ នៃកិច្ចព្រមព្រៀងនេះ និងស្របតាមកតិកាសញ្ញានៃអង្គការសហប្រជាជាតិ [បញ្ជាក់បន្ថែម]”។</td></tr>
<tr><th colspan="2">សមិតភាព</th></tr>
<tr><td colspan="2">ខណៈដែលលិខិតុបករណ៍ទាំងពីរសុទ្ធតែមានបទប្បញ្ញត្តិដោះស្រាយវិវាទ វាមានភាពខុសប្លែកគួរឱ្យកត់សម្គាល់រវាងកាតព្វកិច្ច និងនីតិវិធីក្នុង UNWC និងកិច្ចព្រមព្រៀងទន្លេមេគង្គ។ ក្រោមមាត្រា ៣៣ UNWC មានចែងពីលំដាប់ជំហានលម្អិត និងសមហេតុផលជាមួយនឹងវេទិកាភ្ជាប់កាតព្វកិច្ច ឬមិនភ្ជាប់កាតព្វកិច្ចមួយចំនួនសម្រាប់ការដោះស្រាយវិវាទ ដែលបង្ហាញពីការស្វែងរកការពិត ការផ្តល់យោបល់ជាយុទ្ធសាស្រ្ត ការគ្រប់គ្រងវិបត្តិ និងដំណោះស្រាយវិវាទដែលបង្កើតថ្មី។ ក្របខណ្ឌច្បាប់នេះត្រូវបានពង្រឹងបន្ថែមដោយឧបសម្ព័ន្ធគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងមជ្ឈត្តវិនិច្ឆ័យ និងមាត្រា ៣២ ដែលបានផ្តល់ឱ្យបុគ្គលក្នុងប្រទេសផ្លូវទឹកដែលទទួលរង ឬស្ថិតក្រោមការគំរាមកំហែងដែលជិតកើតឡើងនៃព្យសនកម្ម នូវសិទ្ធិក្នុងការស្វែងរកទំនួលខុសត្រូវនៅក្នុងយុត្តាធិការដែលព្យសនកម្មនោះបានអះអាងថាបានកើតឡើង។ ផ្ទុយមកវិញ កិច្ចព្រមព្រៀងទន្លេមេគង្គផ្តល់ឱ្យប្រទេសសមាជិក និង MRC នូវនីតិវិធីទូទៅមួយចំនួនដោយទុកការបកស្រាយរបស់ពួកគេបើកចំហ និងរក្សានូវការផ្តោតលើដំណើរការដែលពុំភ្ជាប់កាតព្វកិច្ច។</td></tr>
</table>

## 3 អភិបាលកិច្ចគាំទ្ររបស់ UNWC ក្នុងតំបន់ទន្លេមេគង្គ និងក្រៅតំបន់

ផ្អែកលើការវិភាគផ្នែកច្បាប់ដែលបានប្រៀបធៀបខាងលើ និងទម្ងន់បន្ថែមនៃគោលការណ៍ចម្បង និងនីតិវិធីនៃច្បាប់អន្តរជាតិជាប្រពៃណីដែលវាពាក់ព័ន្ធនឹងច្បាប់ស្តីពីទឹកអន្តរជាតិក្នុងលិខិតុបករណ៍ទាំងពីរ មានការរកឃើញទូទៅមួយនៃសមិតភាពផ្នែកច្បាប់ទាំងស្រុងរវាង UNWC និងកិច្ចព្រមព្រៀង មេគង្គ។

ទោះជាយ៉ាងណាក៏ដោយ វាមានលក្ខណៈច្បាស់លាស់ថា កិច្ចព្រមព្រៀងមេគង្គ គឺខុសពី UNWC ទាំងធាតុ និងនីតិវិធីក្នុងទស្សនៈសំខាន់ជាច្រើន។ ម្យ៉ាងវិញទៀត វាមានសមាសធាតុផ្នែកច្បាប់យ៉ាងសំខាន់មួយចំនួនដែលខ្វះខាត ឬមិនគ្រប់គ្រាន់ក្នុងគោលការណ៍ និងធាតុទូទៅនៃនីតិវិធី ដូចបានគាត់តែងក្នុងកិច្ចព្រមព្រៀងមេគង្គ ដោយប្រៀបធៀបជាមួយនឹង UNWC និងច្បាប់អន្តរជាតិជាប្រពៃណីផ្សេងទៀត។ ទោះបីជា គោលដៅនៃកិច្ចព្រមព្រៀង គឺដើម្បីមានគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាពក៏ដោយ គោលការណ៍នានានៃការប្រើប្រាស់ស្មើភាព ការចូលរួមស្មើភាព និងព្យសនកម្មធ្ងន់ធ្ងរ គឺមិនត្រូវបានចែងឱ្យបានគ្រប់គ្រាន់ក្នុងបទប្បញ្ញត្តិនានានៃកិច្ចព្រមព្រៀង ឬមានគុណវឌ្ឍិគ្រប់គ្រាន់យោងតាមអធិបតេយ្យភាពដែនដីឡើយ។ ការបញ្ចូលគ្នានេះគឺធ្វើឱ្យបាត់បង់នូវនីតិវិធីនានាដែលពាក់ព័ន្ធនឹងការជូនដំណឹងជាមុន សម្រាប់ប្រទេសដែលពិចារណាទៅលើគម្រោងដែលមានសក្តានុពលផលប៉ះពាល់ទៅលើប្រទេសផ្សេងទៀត ហើយពុំមានយន្តការ និងនីតិវិធីដោះស្រាយភ្ជាប់កាតព្វកិច្ចចុងក្រោយ និងច្បាស់លាស់ឡើយ។ និយាយជារួម ភាពខុសប្លែកគ្នានៃធាតុ និងស្តង់ដារដែលអាចប្រៀបធៀបបាននៃ UNWC ទាំងនេះ អាចបន្សោយនូវសមត្ថភាពនៃកិច្ចព្រមព្រៀងមេគង្គក្នុងការធ្វើនិយ័តកម្មការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃទន្លេមេគង្គ និងដៃទន្លេនានា។

ដោយត្រូវបានកំណត់ជាកិច្ចព្រមព្រៀងក្របខណ្ឌមួយ ទោះបីជាយ៉ាងណាក៏ដោយ UNWC អាចផ្តល់នូវការណែនាំ ដំណើរការ និងស្តង់ដារសំខាន់ៗក្នុងធាតុច្បាប់សំខាន់ៗទាំងនោះក្នុងតំបន់អាងទន្លេមេគង្គ។ លទ្ធផលដែលបានមកវិញគឺ ឥទ្ធិពលបទដ្ឋាននៃប្រទេសក្នុងតំបន់អាងទន្លេមេគង្គដែលផ្តល់សច្ចាប័នលើ UNWC នឹងទទួលបានអត្ថប្រយោជន៍ចំពោះអភិបាលកិច្ចនៃផ្លូវទឹកអន្តរជាតិជាសកល។ ផ្នែកខាងក្រោមបង្ហាញនូវវិធីដែលប្រទេសក្នុង MRC ដែលផ្តល់សច្ចាប័នលើ UNWC អាចទទួលបាន។

### 3.1 គំលាតដោះស្រាយក្នុងកិច្ចព្រមព្រៀងមេគង្គ និង MRC

ការវិភាគផ្នែកច្បាប់ដែលអាចប្រៀបធៀបបានកាលពីមុននៃកិច្ចព្រមព្រៀងមេគង្គ និងនីតិវិធីពាក់ព័ន្ធដែលជាសសរស្តម្ភចម្បងនៃច្បាប់ស្តីពីទឹកអន្តរជាតិ ជាពិសេស UNWC បានផ្តល់អនុសាសន៍យ៉ាងច្រើនលើសលប់ថា កិច្ចព្រមព្រៀងត្រូវធ្វើឱ្យស្របនឹងសន្ធិសញ្ញា និងច្បាប់អន្តរជាតិជាប្រពៃណីដែលមានស្រាប់។

ភាគច្រើននៃការសិក្សាទាំងនេះត្រូវបានធ្វើឡើងមុនពេល UNWC ចូលជាធរមាន នៅពេលដែលពុំមានប្រទេសក្នុងតំបន់ទន្លេមេគង្គ ក្រៅពីប្រទេសវៀតណាម បានបោះជំហានយ៉ាងមាំដើម្បីផ្តល់សច្ចាប័នលើ UNWC និងនៅពេលដែលប្រទេសចិនបានបោះឆ្នោតជំទាស់ក្នុងការប្រឆាំង។ ជាលទ្ធផល វាគឺសមហេតុផលដែលផ្តោតទឡ្ហីករណ៍លើការបង្កើនស្តង់ដារច្បាប់ បញ្ជាក់ពីដំណើរការឱ្យបានច្បាស់ និងពង្រឹងកាតព្វកិច្ចនៃកិច្ចព្រមព្រៀងមេគង្គចំពោះ UNWC និងច្បាប់អន្តរជាតិជាប្រពៃណីតាមរយៈការកែសម្រួលបទប្បញ្ញត្តិដែលមានស្រាប់នៃកិច្ចព្រមព្រៀង។

បច្ចុប្បន្ន UNWC បានចូលជាធរមាន ប៉ុន្តែ វានៅតែមានសក្តានុពលក្នុងការពិនិត្យមើលថាតើលិខិតុបករណ៍ទាំងពីរអាចពង្រឹងគ្នាទៅវិញទៅមកតាមរបៀបណាក្នុងតំបន់អាងទន្លេមេគង្គ។ ផ្អែកលើសមិតភាពផ្នែកច្បាប់ទូទៅរវាងលិខិតុបករណ៍ទាំងពីរតាមរយៈបទប្បញ្ញត្តិធាតុ និងនីតិវិធីចម្បង ក្នុងនោះដូចដែលបានត្រួតពិនិត្យខាងលើ វាមានករណីបង្ខិតបង្ខំសម្រាប់ប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោមក្នុងការផ្តល់សច្ចាប័នលើ UNWC ដូច្នេះ វាអាចប្រតិបត្តិអែបតាមកិច្ចព្រមព្រៀងទន្លេមេគង្គបាន ព្រមទាំងបញ្ជាក់ និងពង្រឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ជាជាងជំនួសបទប្បញ្ញត្តិទាំងនោះ។

ពីមួយទៅមួយ កិច្ចព្រមព្រៀងមេគង្គអាចត្រូវបានឱ្យតម្លៃ និងប្រើប្រាស់សម្រាប់អ្វីដែលហៅថា សេចក្តីថ្លែងការណ៍ទូលំទូលាយនៃគោលបំណងដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងតំបន់ទន្លេមេគង្គ។ ម្យ៉ាងវិញទៀត MRC ក៏អាចនឹងត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពជាយានជំនិះសំខាន់សម្រាប់កិច្ចសហប្រតិបត្តិការ ដែលនាំប្រទេសនានាក្នុងតំបន់ទន្លេមេគង្គទៅលើគុចរចា ជាជាងត្រឹមតែអង្គភាពដោះស្រាយជម្លោះ។ លើសពីនេះទៅទៀត ការផ្តល់សច្ចាប័នលើ UNWC មិនតំណាងឱ្យបន្ទុកបន្ថែមណាមួយទៅលើប្រទេស

ដែលជាសមាជិក MRC ឡើយ ប្រសិនបើប្រទេសជាសមាជិកបានសម្រេចនូវជំហាននាំមុខនៃកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងទឹក តាមរយៈកិច្ចព្រមព្រៀងមេគង្គ។

### 3.2 UNWC នឹង *ពង្រឹង* មិនមែនជំនួសកិច្ចព្រមព្រៀងមេគង្គឡើយ

ការផ្តល់សច្ចាប័នលើ UNWC នឹងផ្តល់នូវក្របខណ្ឌពង្រឹង និងគាំទ្រសម្រាប់កិច្ចព្រមព្រៀងមេគង្គ និងការណែនាំដែលពុំភ្ជាប់កាតព្វកិច្ច ពាក់ព័ន្ធនឹងការធ្វើនិយ័តកម្មគម្រោងអភិវឌ្ឍវារីអគ្គិសនីលើខ្សែទឹកខាងលើនៃទន្លេមេគង្គ និងដៃទន្លេនានា។ វានឹងពង្រឹង ជាជាងជំនួស ឱ្យកិច្ចព្រមព្រៀងមេគង្គ ព្រមទាំងនីតិវិធី និងការណែនាំដែលពាក់ព័ន្ធ ហើយនឹងបង្កើតនូវស្ថាបត្យកម្មច្បាប់ ផ្សំគ្នានូវច្បាប់ "រឹង" និង "ទន់" សម្រាប់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាពនៃតំបន់អាងទន្លេមេគង្គ។

### 3.3 UNWC នឹង *សម្រប* កិច្ចព្រមព្រៀងមេគង្គជាមួយនឹងច្បាប់ប្រពៃណី

តាមរយៈការផ្តល់សច្ចាប័នលើ UNWC ភាគីនៃ MRC នឹងសម្របកិច្ចព្រមព្រៀងមេគង្គ ព្រមទាំងនីតិវិធី និងការណែនាំដែលពាក់ព័ន្ធជាមួយនឹងច្បាប់អន្តរជាតិជាប្រពៃណី។ ជាទូទៅ UNWC គឺជាសេចក្តីថ្លែងការណ៍សារជាថ្មី និងការគាត់តែងនៃច្បាប់អន្តរជាតិជាប្រពៃណីដោយសារវាពាក់ព័ន្ធនឹងផ្លូវទឹកអន្តរជាតិ។ ជាលទ្ធផល វាបានជួយបញ្ជាក់នូវអត្ថន័យច្បាប់ និងខ្លឹមសារជាក់លាក់នៃបទបញ្ញា និងគោលការណ៍ ដែលត្រូវបានទទួលយកយ៉ាងទូលំទូលាយជាច្បាប់អន្តរជាតិជាប្រពៃណី។

តាមរយៈការផ្តល់សច្ចាប័នលើ UNWC ប្រទេសសមាជិក MRC នឹងមិនត្រឹមតែបញ្ជាក់នូវការស្ម័គ្រចិត្តរបស់ខ្លួនក្នុងការប្រកាន់ខ្ជាប់តាមបទបញ្ញា និងគោលការណ៍មានស្រាប់នៃច្បាប់អន្តរជាតិជាប្រពៃណីនោះទេ ថែមទាំងត្រូវពង្រឹងកិច្ចព្រមព្រៀងមេគង្គទៅជាវេទិកាច្បាប់មានស្រាប់សម្រាប់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងស្មើភាពនៃអាងទន្លេមេគង្គទៀតផង។

ជាចុងក្រោយ ក្នុងនាមជាគោលដៅឧបសម្ព័ន្ធចំពោះការផ្តល់សច្ចាប័នលើ UNWC ក្នុងតំបន់អាងទន្លេមេគង្គ និងជាសកល វាគួរតែមានការផ្តោតស្របគ្នាមួយទៅលើការពង្រឹងច្បាប់ក្នុងប្រទេសដែលអាចអនុវត្តបាន ដើម្បីសម្របទៅតាមបទប្បញ្ញត្តិនៃ UNWC និងវិភាគថាតើការផ្តល់សច្ចាប័នលើ UNWC នឹងមានឥទ្ធិពលទៅវិញទៅមកជាមួយច្បាប់ជាតិ និងច្បាប់ទ្វេភាគី/ពហុភាគីអាចពាក់ព័ន្ធគ្នាយ៉ាងដូចម្តេច។

ដោយពុំគិតដល់ថាតើដំណើរការនៃការផ្តល់សច្ចាប័នជាតិត្រូវចំណាយពេលយូរប៉ុណ្ណានោះ ប្រទេសក្នុងតំបន់អាងទន្លេមេគង្គគួរចាប់ផ្តើមសកម្មភាពដើម្បីពង្រឹងនីតិកម្មក្នុងប្រទេសរបស់ខ្លួនជាមួយនឹងគោលបំណងនៃការសម្របតាមគោលការណ៍ និងបទប្បញ្ញត្តិនៃ UNWC (ដែលបានភ្ជាប់កាតព្វកិច្ចចំពោះពួកគេដូចច្បាប់អន្តរជាតិជាប្រពៃណីដែរ)។ ស្របពេលជាមួយគ្នា ប្រទេសជាសមាជិកដែលមិនទាន់បានអនុវត្តនៅឡើយនោះ ក៏អាចយកឱកាសនេះដើម្បីអនុម័តនីតិកម្មជាក់លាក់ដើម្បីឯកភាពលើកិច្ចព្រមព្រៀងមេគង្គផងដែរ និងដើម្បីបើកផ្លូវឱ្យកិច្ចព្រមព្រៀងអាចត្រូវបានឯកភាពក្នុងយុត្តាធិការជាក់លាក់ដោយស្របគ្នា។

### 3.4 UNWC នឹង *ពង្រឹង* មិនមែនបន្ធោយអាណត្តិ MRC ដើម្បីគ្រប់គ្រងឡើយ

ភាគីប្រទេសក្នុងកិច្ចព្រមព្រៀងមេគង្គដែលបានផ្តល់សច្ចាប័នលើ UNWC នឹងពង្រឹង *មិនមែន* បន្ធោយអាណត្តិច្បាប់ទាំងមូលនៃ MRC ដើម្បីគ្រប់គ្រងការប្រើប្រាស់ស្មើភាព និងសមហេតុផល និងការអភិវឌ្ឍប្រកបដោយចីរភាពនៃខ្សែទឹកចម្បងទន្លេមេគង្គ និងដៃទន្លេនានាឡើយ។ ការផ្តល់សច្ចាប័នលើ UNWC នឹងផ្តល់នូវវេទិកាច្បាប់រួមមួយជាមួយនឹងបទប្បញ្ញត្តិភ្ជាប់កាតព្វកិច្ច និងនីតិវិធីច្បាស់លាស់ជាពិសេសពាក់ព័ន្ធនឹងស្តង់ដារ និងដំណើរការជូនដំណឹង និងពិគ្រោះយោបល់ជាមុន ព្រមទាំងយន្តការដោះស្រាយជម្លោះតតិយជនដែលអាចពង្រឹង MRC ឱ្យប្រតិបត្តិមុខងាររបស់ខ្លួនកាន់តែប្រសើរក្នុងនាមជាស្ថាប័នតំបន់អាងទន្លេ។

ជាពិសេស ការផ្តល់សច្ចាប័នលើ UNWC នឹងមានអត្ថប្រយោជន៍ទ្វេក្នុង៖ ការការពារសិទ្ធិ និងភារកិច្ចដែលមានស្រាប់របស់ប្រទេសជាសមាជិក MRC ស្របតាមកិច្ចព្រមព្រៀងមេគង្គ ទាំងប្រទេសចិន និងប្រទេសភូមាក្នុងនាមជាប្រទេសក្នុងតំបន់អាង ហើយស្របពេលជាមួយគ្នា ក៏ពង្រឹងនូវអាណត្តិស្របច្បាប់នៃ MRC និងប្រទេសជាសមាជិករបស់ខ្លួនតាមរយៈការផ្តល់ឱ្យពួកគេនូវគោលការណ៍ និងកាតព្វកិច្ចនានាដែលបានចរចា និងឯកភាពជាសកល ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថាភ្ជាប់កាតព្វកិច្ចចំពោះប្រទេសទាំងអស់ដែលនៅក្រៅវិសាលភាពកំណត់នៃកិច្ចព្រមព្រៀងមេគង្គ។ លើសពីនេះទៅទៀត UNWC នឹងជួយដោះស្រាយគំលាតចម្បងមួយក្នុងចំណោមជាច្រើននៅក្នុងអាណត្តិស្របច្បាប់ដែលមានស្រាប់នៃ MRC ដែលបន្តប្រជែងជាពិសេសចំពោះអភិបាលកិច្ចទូទាំងតំបន់អាងប្រកបដោយប្រសិទ្ធភាព៖ អវត្តមាននៃប្រទេសនៅតំបន់អាងខ្សែទឹកខាងលើក្នុងកិច្ចព្រមព្រៀង រួមមានប្រទេសចិន និងប្រទេសភូមា។

ការផ្តល់សច្ចាប័នលើ UNWC នឹងបង្កើតនូវវេទិកាច្បាប់រួមដែលត្រូវបានទទួលស្គាល់ជាសកល និងផ្ទុកនូវគោលការណ៍ និងនីតិវិធីច្បាប់អន្តរជាតិជាប្រពៃណីដែលភ្ជាប់កាតព្វកិច្ច ជាពិសេស ពាក់ព័ន្ធនឹងការដោះស្រាយជម្លោះ។ វានឹងមានប្រយោជន៍ចំពោះប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោមក្នុងការចរចាជាមួយនឹងប្រទេសក្នុងតំបន់អាងទន្លេមេគង្គលើតាមរយៈ MRC។

UNWC *ការពារ* អាណត្តិមានស្រាប់នៃ MRC និងប្រទេសជាសមាជិកតាមរយៈបទប្បញ្ញត្តិសំខាន់ៗ។ ទីមួយ UNWC មានចែងច្បាស់អំពីលក្ខណៈច្បាប់នៃសិទ្ធិ និងភារកិច្ចចេញពីកិច្ចព្រមព្រៀងផ្លូវទឹកដែលមានស្រាប់។ ទីពីរ UNWC មានចែងច្បាស់អំពីលក្ខណៈច្បាប់នៃសិទ្ធិ និងភារកិច្ចពាក់ព័ន្ធនឹងសភាពផ្លូវទឹកជាទូទៅ។ ទីបី UNWC នឹងពង្រឹងអាណត្តិនៃ MRC នាពេលកន្លងមក ដោយសារវាបង្ខាំងនូវខ្សែទឹកចម្បង និងដៃទន្លេនៃទន្លេអន្តរជាតិតាមរយៈការកំណត់នូវភាពខុសប្លែកគ្នាផ្លូវច្បាប់រវាងផ្នែកទាំងពីរ។

និយាយអំពីការពង្រឹងអាណត្តិស្របច្បាប់នៃ MRC និងប្រទេសជាសមាជិកដើម្បីគ្រប់គ្រងខ្សែទឹកចម្បងនៃទន្លេមេគង្គ និងដៃទន្លេឱ្យមានប្រសិទ្ធភាព ភាគីនៃកិច្ចព្រមព្រៀងមេគង្គអាចទាញយកឯកសារយោងពីការផ្តល់សច្ចាប័នលើ UNWC និងការអនុវត្តន៍នៃបទប្បញ្ញត្តិដោយតំបន់អាងទន្លេឆ្លងដែនទូទាំងពិភពលោក។ ចាប់តាំងពីការអនុម័ត និងការផ្តល់សច្ចាប័នជាបន្តបន្ទាប់ដោយ UNGA រួចមក UNWC ដែលជា*អនុសញ្ញាក្របខណ្ឌ* បានបញ្ជាក់នូវឥទ្ធិពលលើកិច្ចព្រមព្រៀងជាក់លាក់ និងទ្វេភាគីស្តីពីតំបន់ និងតំបន់អាងទន្លេ។ សហគមន៍អភិវឌ្ឍអាហ្វ្រិកខាងត្បូង 2000 (SADC) បានកែសម្រួលនូវពិធីសារស្តីពីការចែករំលែកផ្លូវទឹក ដែលបានជំនួសនូវពិធីសារឆ្នាំ ១៩៩៥ ដែលមានឈ្មោះដូចគ្នា ដើម្បីប្រើនូវពាក្យ UNWC ដដែល ដែលជាឧទាហរណ៍មួយនៃការឈានដល់ និងការទទួលស្គាល់ជាសកលនៃអនុសញ្ញា។

### 3.5 UNWC នឹង*ពង្រឹង* មិនមែនបន្ធោយកិច្ចសហប្រតិបត្តិការក្នុង និងតាមរយៈ MRC ឡើយ

ការផ្តល់សច្ចាប័នលើ UNWC នឹងពង្រឹង *មិនមែន* បន្ធោយកាតព្វកិច្ចសហការ នីតិវិធី និងវិធានការគោលនយោបាយដែលធ្វើឡើងដោយ MRC និងប្រទេសជាសមាជិកឡើយ។ ពីមួយទៅមួយ វានឹងពង្រឹងនូវអភិបាលកិច្ចទាំងមូលក្នុងតំបន់ទន្លេមេគង្គ ពីព្រោះការផ្តល់សច្ចាប័នលើ UNWC នឹងផ្តល់នូវស្តង់ដារបន្ទាត់មូលដ្ឋានច្បាប់ ក្របខណ្ឌពេលវេលា និងនីតិវិធីដែលស៊ីគ្នាសម្រាប់កិច្ចសហប្រតិបត្តិការរវាងប្រទេសដែលជាសមាជិក។

គោលបំណងសំខាន់ជាងគេនៃផ្នែកទី ៣ នៃ UNWC គឺដើម្បីអនុញ្ញាតឱ្យមានការដោះស្រាយដែលស៊ីគ្នា និងមានតម្លាភាពរវាងប្រទេសនានាពាក់ព័ន្ធនឹងគម្រោងដែលអាចបង្កឱ្យមានរឿងចម្រូងចម្រាស។ ហេតុដូច្នេះ UNWC អាចជួយកាត់បន្ថយនូវភាពមានន័យមិនច្បាស់លាស់ទូទៅទាំងមូលតាមរយៈការផ្តល់ឱ្យនូវការបង្ហាញឱ្យច្បាស់អំពី "ក្រមសីលធម៌" ដែលក្នុងនោះ ប្រទេសដែលជូនដំណឹង និងត្រូវទទួលបានការជូនដំណឹងអាចសហការ និងចូលរួមបាន។ ដោយពិចារណាទៅលើលក្ខណៈច្បាប់ដែលទំនងជាគ្មានភ្ជាប់កាតព្វកិច្ចនៃ PNCPA នៃកិច្ចព្រមព្រៀង មេគង្គ និងការណែនាំដែលពាក់ព័ន្ធ វាមានសារៈសំខាន់ដែលថា កិច្ចព្រមព្រៀងអាចពង្រឹងកាតព្វកិច្ចខាងនីតិវិធីរបស់ខ្លួនក្នុងបរិបទនេះ។

ម្យ៉ាងវិញទៀត វាមានប្រយោជន៍សេដ្ឋកិច្ចប្រកបដោយសក្តានុពលជាច្រើនដែលបានផ្តល់ឱ្យប្រទេសនានាតាមរយៈការមានផ្លូវធ្វើដំណើរច្បាស់លាស់ ព្រមទាំងនីតិវិធីភ្ជាប់កាតព្វកិច្ច ស្តង់ដារ និងការរំពឹងទុកដើម្បីកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍវារីអគ្គិសនីក្នុងតំបន់អាងទន្លេមេគង្គ ជាពិសេស ពាក់ព័ន្ធនឹងនីតិវិធីសម្រាប់ការជូនដំណឹង និងការពិគ្រោះយោបល់ជាមុនទាក់ទងនឹងវិធានការគ្រោងទុកសម្រាប់គម្រោងដែលមានផលប៉ះពាល់ឆ្លងដែនដែលអាចទៅរួច។ កិច្ចសហប្រតិបត្តិការនឹងត្រូវបានគាំទ្របន្ថែមទៀតតាមរយៈការលើកកម្ពស់ការយល់ដឹង និងការផ្តល់ឱ្យនូវការកសាងសមត្ថភាពបច្ចេកទេសលើ UNWC ក្នុងចំណោមប្រទេសសមាជិក MRC ។

## 4 សេចក្តីសន្និដ្ឋាន និងអនុសាសន៍

២០ ឆ្នាំក្រោយពីកិច្ចព្រមព្រៀង មេគង្គត្រូវបានអនុម័តដោយប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោម រួមមាន ប្រទេសកម្ពុជា សាធារណ-រដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រទេសថៃ និងប្រទេសវៀតណាមរួច ការផ្តល់សច្ចាប័នលើ UNWC ដោយប្រទេសវៀតណាមបង្ហាញនូវឱកាសមួយក្នុងការចាប់យកដំណោះស្រាយផ្សេងដើម្បីពង្រឹងអភិបាលកិច្ចទឹកឆ្លងដែនក្នុងតំបន់អាងទន្លេមេគង្គ និងទូទាំងសកល។

វាមានសារៈសំខាន់ក្នុងការធ្វើកំណត់សម្គាល់ថា ប្រទេសទាំងអស់ក្នុងតំបន់អាងទន្លេគឺត្រូវបានភ្ជាប់កាតព្វកិច្ចរួចទៅហើយដោយគោលការណ៍នៃច្បាប់ប្រពៃណីអន្តរជាតិដែលត្រូវបានតាក់តែងឡើងក្រោម UNWC។ ជាលទ្ធផល ប្រទេសនានាដែលផ្តល់សច្ចាប័ន និង

អនុវត្ត UNWC នឹងមើលឃើញថាពុំមានការផ្លាស់ប្តូរក្នុងកាតព្វកិច្ចជាមូលដ្ឋានរបស់ពួកគេឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគេនឹងទទួលបានប្រយោជន៍ពីក្របខណ្ឌដែលអាចអនុវត្តបាន ដែលបច្ចុប្បន្នពុំមាននៅក្នុងកិច្ចព្រមព្រៀងមេគង្គ។ វានឹងផ្តល់នូវភាពស្របគ្នាទូទាំងតំបន់អាងទន្លេទាំងមូលក្នុងអភិបាលកិច្ច និងនិយ័តកម្មប្រកបដោយប្រសិទ្ធភាពនៃការអនុវត្តន៍របស់ប្រទេសនៅតាមដងទន្លេ។

ភាពអាចអនុវត្តបាននៃ UNWC នឹងត្រូវបានពង្រឹងបន្ថែមតាមរយៈសន្ធិសញ្ញា ប្រពៃណីអន្តរជាតិ និងសេចក្តីសម្រេចរបស់ ICJ ដែលមានស្រាប់ និងនៅថ្ងៃអនាគត។ តាមលក្ខណៈរបស់វា អនុសញ្ញាក្របខណ្ឌនេះផ្តល់នូវមូលដ្ឋានកណ្តាលដើម្បីឱ្យច្បាប់អន្តរជាតិកសាងភាពដូចគ្នាទូទាំងតំបន់អាងទាំងមូលសម្រាប់ MRC និងប្រទេសដែលជាសមាជិក។ ខណៈដែលលក្ខណៈទូទៅវិញ UNWC ផ្តល់នូវភាពច្បាស់លាស់ពាក់ព័ន្ធនឹងការអនុវត្តន៍នៃច្បាប់ស្តីពីទឹកអន្តរជាតិ ដែលសន្ធិសញ្ញាស្តីពីអាងទន្លេ និង/ឬ ផ្លូវទឹកក្នុងបរិបទអាចផ្តល់នូវយន្តការគ្រប់គ្រងកាន់តែប្រសើរឡើង។

បន្ថែមពីនេះ ការផ្តល់សច្ចាប័នលើ UNWC នឹងគាំទ្រដល់ប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោម ពីព្រោះប្រទេសទាំងនេះស្វែងរកកិច្ចពិភាក្សាប្រកបដោយតុល្យភាពបន្ថែមជាមួយនឹងប្រទេសខ្សែទឹកខាងលើដែលនៅមិនទាន់ក្លាយទៅជាផ្នែកនៃកិច្ចព្រមព្រៀងមេគង្គ និង MRC នៅឡើយ។

អត្ថប្រយោជន៍នៃការផ្តល់សច្ចាប័ននឹងពង្រីកទៅក្រៅតំបន់ទន្លេមេគង្គផងដែរ។ UNWC នៅតែត្រូវធ្វើសច្ចាប័នបន្ថែមទៀតដើម្បីឱ្យឥទ្ធិពលរយៈពេលវែងរីករាលដាលលើការអនុវត្តន៍នៃប្រទេសនៅតាមដងទន្លេទូទាំងពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់សច្ចាប័នដោយប្រទេសក្នុងតំបន់អាងទន្លេមេគង្គនឹងផ្តល់នូវភាពស៊ីគ្នានៃដំណោះស្រាយក្នុងការចរចាលើវិធានការភ្ជាប់កាតព្វកិច្ចសម្រាប់ការគ្រប់គ្រង និងការប្រើប្រាស់នៃផ្លូវទឹកអន្តរជាតិ។ ដោយសារដំណោះស្រាយនេះកាន់តែទូលំទូលាយទៅ វាអាចធ្វើជាភស្តុតាងលក្ខណៈបង្ហំបន្ថែមទៀតសម្រាប់សារៈសំខាន់នៃការអនុម័តច្បាប់អន្តរជាតិជាប្រពៃណី។ វឌ្ឍនភាពជាបន្តបន្ទាប់នៃការអភិវឌ្ឍពិធីសារ/សន្ធិសញ្ញាការអនុម័តវិធានការភ្ជាប់កាតព្វកិច្ច និងតាមពេលវេលា ដែលលើកតម្កើងនូវស្តង់ដារនៃប្រពៃណីអន្តរជាតិពាក់ព័ន្ធនឹងការប្រើប្រាស់ការគ្រប់គ្រង និងអភិបាលកិច្ចនៃផ្លូវទឹកឆ្លងដែន នឹងជួយធ្វើឱ្យប្រសើរឡើងនូវការអនុវត្តន៍របស់ប្រទេសនៅតាមដងទន្លេក្នុងតំបន់ទន្លេមេគង្គ និងទូទាំងពិភពលោក។

### 4.1 អនុសាសន៍ចម្បង

បន្ទាប់ពីការវិភាគប្រៀបធៀបលម្អិតនៃគោលការណ៍ និងកាតព្វកិច្ចនៃធាតុ និងនីតិវិធីចម្បងរបស់ UNWC និងកិច្ចព្រមព្រៀងមេគង្គមានការរកឃើញនៃការអាចប្រៀបធៀបផ្នែកច្បាប់ទូទៅទាំងមូលរវាងលិខិតុបករណ៍ទាំងពីរ។ ម្យ៉ាងវិញទៀត នៅពេលមានគំលាត និងភាពមិនស្របគ្នា UNWC ដែលជាអនុសញ្ញាក្របខណ្ឌសកលទទួលស្គាល់ជាអន្តរជាតិលើអភិបាលកិច្ចផ្លូវទឹកឆ្លងដែន អាចជួយបំពេញគំលាតទាំងនោះបាន។ វាមានសារៈសំខាន់ជាពិសេសក្នុងតំបន់នៃនីតិវិធីសម្រាប់ការជូនដំណឹង និងការពិគ្រោះយោបល់ជាមុនដែលមានលក្ខណៈសំខាន់សម្រាប់ការដោះស្រាយវិវាទ។

នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងកិច្ចព្រមព្រៀង (PNCPA) នៃកិច្ចព្រមព្រៀងមេគង្គ គឺជាផ្នែកខាងក្រៅនៃកិច្ចព្រមព្រៀង ហើយជាលទ្ធផលគឺពុំមានជាប់កាតព្វកិច្ចឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ គំលាតក្នុងភាពអាចអនុវត្តបាននេះត្រូវបានដោះស្រាយដោយបទប្បញ្ញត្តិច្បាប់ច្បាស់លាស់នៃ UNWC ក្នុងបរិបទនេះ។

ពីមួយទៅមួយ UNWC នឹងពង្រឹង ជាជាងជំនួសឱ្យកិច្ចព្រមព្រៀង មេគង្គ និង MRC ព្រមទាំងពង្រឹងឥទ្ធិពលបទដ្ឋានទូលំទូលាយរបស់វាឱ្យទៅជាលិខិតុបករណ៍ផ្លូវច្បាប់សំខាន់បំផុតសម្រាប់អភិបាលកិច្ចនៃផ្លូវទឹកឆ្លងដែនជាសកល។

ដើម្បីឱ្យ UNWC មានប្រសិទ្ធភាពទាំងស្រុងក្នុងការពង្រឹងកិច្ចព្រមព្រៀងមេគង្គ ទោះបីជាយ៉ាងណាក៏ដោយ ការផ្តល់សច្ចាប័នជាសកលលើ UNWC ដោយប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោម និងប្រទេសជាសមាជិកផ្សេងទៀតនៃ MRC គឺត្រូវការជាចាំបាច់ ដោយលាតសន្ធឹងដល់ប្រទេសក្នុងតំបន់អាងទន្លេខ្សែទឹកខាងលើ រួមមានប្រទេសចិន និងប្រទេសភូមា។

ការផ្តល់សច្ចាប័នលើ UNWC ត្រូវបានផ្តល់អនុសាសន៍ឱ្យធ្វើ ដោយសារមូលហេតុដូចខាងក្រោម៖

- ***ពង្រឹង* មិនមែនជំនួសឱ្យកិច្ចព្រមព្រៀង មេគង្គឡើយ**

    - ការផ្តល់សច្ចាប័នលើ UNWC នឹងផ្តល់នូវក្របខណ្ឌពង្រឹង និងគាំទ្រសម្រាប់កិច្ចព្រមព្រៀងមេគង្គ និងការណែនាំពុំភ្ជាប់កាតព្វកិច្ចដែលមានសារៈសំខាន់ក្នុងការធ្វើនិយ័តកម្មលើគម្រោងអភិវឌ្ឍវារីអគ្គិសនីតាមដងទន្លេមេគង្គ និងដៃទន្លេ។

    - លទ្ធផលនៃការផ្តល់សច្ចាប័នដោយប្រទេសនានានឹងបង្កើតនូវស្ថាបត្យកម្មច្បាប់រួមគ្នានូវច្បាប់រឹង និងច្បាប់ទន់ដើម្បីការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវអាងទន្លេមេគង្គ។

- ***សម្រប* កិច្ចព្រមព្រៀង មេគង្គជាមួយនឹងច្បាប់អន្តរជាតិជាប្រពៃណី**

    ការផ្តល់សច្ចាប័នដោយប្រទេសជាសមាជិក MRC នឹងបញ្ជាក់ពីគោលបំណងរបស់ពួកគេក្នុងការប្រកាន់ខ្ជាប់តាមបទបញ្ញា និងគោលការណ៍នៃច្បាប់អន្តរជាតិជាប្រពៃណីដែលមានស្រាប់ ខណៈដែរពង្រឹងកិច្ចព្រមព្រៀងមេគង្គទៅជាវេទិកាច្បាប់មានស្រាប់សម្រាប់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព និងស្មើភាពនៃតំបន់អាងទន្លេ។

- ***ពង្រឹង* សមត្ថភាពនៃ MRC ដើម្បីគ្រប់គ្រង**

    - ការផ្តល់សច្ចាប័នលើ UNWC ដោយប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោមទាំងអស់នឹងមានប្រយោជន៍ទ្វេគឺះ ការការពារសិទ្ធិ និងភារកិច្ចដែលមានស្រាប់របស់ប្រទេសជាសមាជិក MRC ស្របតាមកិច្ចព្រមព្រៀងមេគង្គ ទាំងប្រទេសចិន និងប្រទេសភូមាកក្នុងនាមជាប្រទេសក្នុងតំបន់អាង ហើយស្របពេលជាមួយគ្នាក៏ពង្រឹងនូវអាណត្តិស្របច្បាប់នៃ MRC និងប្រទេសជាសមាជិករបស់ខ្លួនតាមរយៈការផ្តល់ឱ្យពួកគេនូវគោលការណ៍ និងកាតព្វកិច្ចនានាដែលបានចរចា និងឯកភាពជាសកល ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិថាភ្ជាប់កាតព្វកិច្ចចំពោះប្រទេសទាំងអស់ដែលនៅក្រៅវិសាលភាពកំណត់នៃកិច្ចព្រមព្រៀងមេគង្គ។

    - ការផ្តល់សច្ចាប័ននឹងបញ្ជាក់នូវការប្តេជ្ញារបស់ប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោមក្នុងការធ្វើឱ្យប្រសើរឡើងនូវដំណើរការ និងតម្លាភាព ស្របតាមច្បាប់អន្តរជាតិជាប្រពៃណី។

    - ទោះបីជាមានការអវត្តមានជាបន្តបន្ទាប់របស់ប្រទេសចិន និងប្រទេសភូមាក្នុង MRC ក៏ដោយវានៅតែមានអត្ថប្រយោជន៍ច្បាស់លាស់ក្នុងប្រទេសនៃតំបន់អាងទន្លេមេគង្គក្រោមដែលបានផ្តល់សច្ចាប័នលើ UNWC ជាពិសេស ប្រសិនបើសមាជិក MRC ទាំងអស់ផ្តល់សច្ចាប័ន។ វានឹងបង្កើតនូវវេទិកាច្បាប់រួមមួយដែលត្រូវបានទទួលស្គាល់ជាសកល និងផ្ទុកនូវគោលការណ៍ និងនីតិវិធីអន្តរជាតិប្រពៃណីដែលភ្ជាប់កាតព្វកិច្ចពិសេស ពាក់ព័ន្ធនឹងការដោះស្រាយវិវាទ ដែលប្រទេសក្នុងតំបន់អាងទន្លេមេគង្គក្រោមអាចប្រើប្រាស់ក្នុងការចរចាជាមួយប្រទេសក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងលើបានតាមរយៈ MRC ។

- ***ពង្រឹង* មិនមែនបន្ធោយកិច្ចសហប្រតិបត្តិការក្នុង និងតាមរយៈ MRC ឡើយ**

    - UNWC ផ្ទុកនូវនីតិវិធីដោះស្រាយជម្លោះដែលបានកំណត់យ៉ាងច្បាស់លាស់ និងប្រកបដោយតម្លាភាព ដែលអាចផ្តល់នូវបទប្បញ្ញត្តិ និងក្របខណ្ឌច្បាប់ស៊ីគ្នាដើម្បីពង្រឹងនូវយន្តការដោះស្រាយវិវាទក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គខណៈដែលនៅរក្សាទុកនូវអាណត្តិ MRC ជាយានជំនិះសម្រាប់កិច្ចសហប្រតិបត្តិការ និងការចរចាក្នុងតំបន់អាងទន្លេ។

    - នីតិវិធីជូនដំណឹង និងពិគ្រោះយោបល់ជាមុនដែលភ្ជាប់កាតព្វកិច្ចរបស់ UNWC សម្រាប់វិធានការដែលបានគ្រោងទុកអាចដោះស្រាយគំលាត និងភាពមានន័យមិនច្បាស់នានាក្នុងក្របខណ្ឌ PNCPA ដែលមានស្រាប់ ស្របតាមកិច្ចព្រមព្រៀងមេគង្គ ព្រមទាំងនីតិវិធី និងការណែនាំដែលពាក់ព័ន្ធ និងលក្ខខណ្ឌមិនភ្ជាប់កាតព្វកិច្ច និងកង្វះខាត

នៃតារាងពេលវេលា/ស្តង់ដារក្នុងបរិបទនេះ បានបង្កឱ្យមានការខ្វែងគំនិតគ្នារវាងប្រទេសជាសមាជិក MRC ទាក់ទងនឹងគម្រោងវារីអគ្គិសនី។

- វាមានប្រយោជន៍ផ្នែកសេដ្ឋកិច្ចប្រកបដោយសក្តានុពលជាច្រើន ដែលពាក់ព័ន្ធទៅនឹងការមានដំណើរការជូនដំណឹង និងពិគ្រោះយោបល់ជាមុនដែលបានកំណត់យ៉ាងច្បាស់លាស់ប្រកបដោយតម្លាភាព និងភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ជាពិសេសពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំនានា រួមបញ្ចូលទាំង ទំនប់វារីអគ្គិសនី។

## References


- **Bearden, B.L.** (2010). The legal regime of the Mekong River: a look back and some proposals for the way ahead. *Water Policy*, 12, 798.
- **Bearden, B.L.**, (2012). Following the proper channels: tributaries in the Mekong legal regime. *Water Policy*, 14, 991.
- **Bearden, B.L., Rieu-Clarke, A., & Pech, S.** (2012). Mekong Basin. In *The UN Watercourse Convention in Force: Strengthening International Law for Transboundary Water Management*. (*Routledge, United Kingdom*) 180-188.
- **Browder, G. & Ortolano, L.** (2000). The Evolution of an International Water Resources Management Regime in the Mekong River Basin. *Natural Resources Journal,* 40, 499
- **Brunner, J.** (24 June 2015). Why the region needs the UN Watercourses Convention. *IUCN*. Available at https://www.iucn.org/news_homepage/news_by_date/?21567/Why-the-region-needs-the-UN-Watercourses-Convention
- **Chen, H., Rieu-Clarke, A. & Wouters, P.** (2013). Exploring China's transboundary water treaty practice through the prism of the UN Watercourses Convention ' *Water International* 38(2), 217-230.
- **Higgs, S. (2011).** Analysis of International Environmental Laws Implicated by Decision to Approve Construction of the Xayaburi Dam. October 12, 2011, Prepared for International Rivers & Environmental Defender Law Center. Available at: https://www.internationalrivers.org/files/attached-files/xayaburi_legal_analysis_en.pdf
- **Hirsch, P.** (1999). Nature beyond the nation state symposium: beyond the nation state - natural resource conflict and "national interest" in Mekong hydropower development. *Golden Gate Law Review,* 29, 399.
- **Hirsch, P. & Jensen, K.M.** (2006). National Interests and Transboundary Water Governance in the Mekong. Australian Mekong Resource Centre, University of Sydney, Australia.
- **Jacobs, J.W.** (2002). The Mekong River Commission: Transboundary Water Resources Planning and Regional Security. *The Geographical Journal,* 168(4), 354.
- **Johns, F., Saul, B., Hirsch, P., Stephens, T. & Boer, B**. (2010). Law and the Mekong River Basin: A Social-Legal Research Agenda on the Role of Hard and Soft Law in Regulating Transboundary Water Resources *Melbourne Journal of International Law* 11(1), 154.
- **Lee, G. & Scurrah, N**. (2009). Power and responsibility – The Mekong River Commission and Lower Mekong mainstream dams. *A joint report of the Australian Mekong Resource Centre, Sydney University and Oxfam Australia*. Available at: http://sydney.edu.au/mekong/documents/power_and_responsibility_fullreport_2009.pdf
- **Loures, F., Rieu-Clarke, A.S., & Vercambe. M.L**. (2008) Everything you need to know about the UN Watercourses Convention. *World Wildlife Foundation Series.* Available at: http://www.unwater.org/downloads/wwf_un_watercourses_brochure_for_web_1.pdf
- **McCaffrey, S.** (2001a). International Water Law for the 21st Century: The Contribution of the U.N. Convention. *Water Resources Update,* 118, 11.
- **McCaffrey, S**. (2001b). The Contribution of the UN Convention on the law of the non-navigational uses of international watercourses. *International Journal of Global Environmental Issues,* 1(3/4), 250.
- **McCaffrey, S. C.** (2007). The Law of International Watercourses, 2nd edn. *Oxford University Press, Oxford, UK*.
- **McCaffrey, S.** (2010). Establishing rights: the law of international waters. In Sharing Water, Sharing Benefits— Working Towards Effective Transboundary Water Resources Management: A Graduate/Professional Skills-Building Workbook. Wolf, A. T. (ed.). Adapted from the World Bank International Waters Course. UNESCO and The World Bank Paris and Washington, DC.
- **MRC** (2008). The Story of Mekong Cooperation. Available at: http://www.mrcmekong.org/about_mrc.htm#story
- **Oliver, R.A.R., Moore, P. & Lazarus, K**. eds. (2006). Mekong Region Water Resources Decision-making: National Policy and Legal Frameworks vis-à-vis World Commission on Dams Strategic Priorities, IUCN, Bangkok, Thailand and Gland, Switzerland.
- **Osborne, M.** (2004). River at risk: The Mekong and the water politics of China and Southeast Asia*. Lowy Institute for International Policy Paper 02*. Longueville Media, New South Wales, Australia.

- **Paisley, R.** (2002). Adversaries into partners: international water law and the equitable sharing of downstream benefits. *Melbourne Journal of International Law,* 3, 280.
- **Pech, S**. (2011). UN Watercourses Convention and Greater Mekong Sub-region. July 2011. *Hatfield Consultants*. Available at http://www.unwatercoursesconvention.org/images/2012/10/Mekong-and-UNWC.pdf
- **Pichyakorn, B,** (2005). International Watercourses Law: The experience of the Mekong River Basin, in International Watercourses Law for the 21st Century: The Case of the Ganges River Basin. ed. Surya P. Subedi (Aldershop, Ashgate)
- **Pichyarkon, B** (2002). Sustainable development and international watercourses agreements; the Mekong and the Rhine. IUCN Draft Paper.
- **Pittock, J.** (2009). Renewed hope for UN Watercourses Convention. *Water 21,* 12.
- **Radosevich, G.E., & Olson, D.C (1999).**. Existing and emerging basin arrangements in Asia: Mekong River Commission case study. Paper presented at the Third Workshop on River Basin Institution Development, Washington DC, United States, 24 June 1999.
- **Rieu-Clarke, A.S**. (2001). Globalisation, international watercourses and the sources of international law. Paper presented at the International Water Seminar – Globalisation and Water, Dundee, UK, 6-8 August 2001.
- **Rieu-Clarke, A.** (2015). Transboundary hydropower projects seen through the lens of three international legal regimes: foreign investment, environmental protection and human rights. *International Journal of Water Governance*, 3(1), 27.
- **Rieu-Clarke, A.** (2015). Notification and consultation procedures under the Mekong Agreement: insights from the Xayaburi controversy. *Asian Journal of International Law*, 5(1), 143.
- **Rieu-Clarke, A.** (2014). Notification and Consultation on Planned Measures Concerning International Watercourses: Learning Lessons from the Pulp Mills and Kishenganga Cases. *Yearbook of International Environmental Law 2013*, *24*(1), 102.
- **Rieu-Clarke, A.S**. (2007). Entry into force of the 1997 UN Watercourses Convention: barriers, benefits and prospects. *Water 21,* 12.
- **Rieu-Clarke, A., & Gooch, G.** (2009-2010). Governing the Tributaries of the Mekong-The Contribution of International Law and Institutions to Enhancing Equitable Cooperation Over the Sesan. *Pacific McGeorge Global Business & Development Law Journal,* 22, 193.
- **Rieu-Clarke, Kinna, R., Litke, A**. (2013). UN Watercourses Convention: Online User's Guide, *Centre for Water Law, Policy and Science, University of Dundee*. Available at: www.unwatercoursesconvention.org/
- **Rieu-Clarke, A.S**., **& Loures, F.V.** (2009). Still not in force: Should States support the 1997 UN Watercourses Convention. *World Wildlife Foundation Series.* Available at: http://assets.panda.org/downloads/rieu_clarke_and_loures___final_for_website.pdf
- **Rieu-Clarke, A., Moynihan, R., Magsig, B.O.** (2012). UN Watercourses Convention User's Guide. *IHP-HELP Centre for Water Law, Policy and Science (under the auspices of UNESCO)*. United Kingdom.
- **Salman, S.M.A.** (2007). The United Nations Watercourses Convention ten years later: why has its entry into force proven so difficult? *Water International* 32, 1.
- **Salman, S.M.A.** (2015). Entry into force of the United Nations Watercourses Convention: Why should it matter? *International Journal of Water Resources Development* 32, 1.
- **Sneddon, C., & Fox, C.** (2006). Rethinking transboundary waters: A critical hydropolitics of the Mekong basin. *Political Geography,* 25, 181.
- **Sneddon, C., & Fox, C.** (2007). Transboundary river basin agreements in the Mekong and Zambezi basins: enhancing environmental security or securitizing the environment? *International Environmental Agreements,* 7, 237.
- **Turton, S.** (2015). Mekong body risks losing funds: donors. 25 June 2015. *Phnom Penh Post*. Available at www.phnompenhpost.com/national/mekong-body-risks-losing-funds-donors
- **Van Duyen, N.** (2001). The Inadequacies of Environmental Protection Mechanisms in the Mekong River Basin Agreement. *Asia Pacific Journal of Environmental Law*, 6, 349.
- **Wouters, P.K., Vinogradov, S., Allan, A., Jones, P., Rieu-Clarke, A.** (2005). Sharing Transboundary Waters: An Integrated Assessment of Equitable Entitlement: The Legal Assessment Model. *International Hydrological Programme (IHP) of the United Nations Educational, Scientific and Cultural Organization (UNESCO),* Dundee, Scotland. Available at: http://www.chinainternationalwaterlaw.org/pdf/resources/LegalAssessmentModel-.pdf **WWF**

(2012). UNWC Workshop Summary Report of Regional Awareness Raising Workshop. Available at http://www.unwatercoursesconvention.org/images/2012/10/Summary-report-of-the-Regional-Awareness-Raising-Workshop_May10_20120530-1.pdf

- **WWF** (2012). UNWC Summary National Awareness Raising Workshop Vietnam. Available at http://www.unwatercoursesconvention.org/images/2012/10/Summary-Notes-for-Vietnam-National-Awareness-Raising-Workshops-_Combined-Commentsarc_20120530-1.pdf

INTERNATIONAL UNION
FOR CONVERSATION OF NATURE

Asia Regional Office
63 Sukhumvit Soi 39
Wattana, Bangkok
10110 Thailand
Tel: + 66 2 662 4029
Fax: + 66 2 662 4387
www.iucn.org/asia